វាមានឃ្លាំងមួយទៀតដែលវាលាក់មិនឱ្យនរណា ដឹងកន្លែងទេ ។ ក្រៅពី សាលនឹងគេហដ្ឋានទាំងនោះ មានកំពែងកំពស់បីម៉ែត្រធ្វើអំពីថ្មបាយក្រៀម រៀបជាបួនជ្រុងទ្រវែងព័ទ្ធជុំវិញ ។ កំពែងនេះពួកវាចាក់ដីពីក្នុងយ៉ាងក្រាស់ ដើម្បីការពារគ្រាប់កាំភ្លើងបើសិនជាមាន បាញ់មកពីក្រៅ ។ មានប៉មខ្ពស់ៗ បួននៅគ្រប់ជ្រុងជំរុំ ហើយដាក់មនុស្ស ឱ្យយាម ក្រែងមានសត្រូវមកពីទិស ខាងណា នឹងវាយគងធំដែលគេដាក់ មួយៗទុកឱ្យគ្រប់គ្នា ដើម្បីជាសញ្ញា ទៅក្នុងជំរុំ ។ វត្ថុដែលញ៉ាំងឱ្យមនុស្ស ចំឡែករន្ធត់ជាដំបូងបំផុតនោះគឺទ្វារ ច្រករបងខាងមុខគេធ្វើជារូបក្បាលរាហូយ៉ាងធំសម្បើមបើកភ្នែកក្រឡោត ហាមាត់ជង្គ្រងបញ្ចេញធ្មេញនឹង ចង្កូមសស្ងាច ធ្វើអំពីឈើយ៉ាងរឹងហើយ ស្វិត ។ គេចេញចូលតាមមាត់ រាហូនេះ ដោយគេរវៃខាបង្អើបចង្កូមនឹង ធ្មេញឡើងទៅលើ ។

លុះពួកចោរសែងលោកសុគន្ធាមកដល់ប្របជំរុំនេះហើយ អ្នកយាមប៉មខាងមុខវាយគងមួយអន្លូងយ៉ាងខ្លាំង ។ ពួកចោរដែលទើបនឹង មកដល់ទាំងអស់ ត្រូវអង្គុយចោងហោងគ្រប់គ្នា ទុកឱ្យតែមេក្បួនម្នាក់ ដើរចូលទៅជិតទ្វារ ដើម្បីឱ្យអ្នកយាមមើលសំគាល់ តើជាពួកខ្លួនឬជាពួក ដទៃ ព្រមទាំងសាកសួរតើមានហេតុ ឬត្រូវការយ៉ាងណា ។ ទុកជា មើលគ្នាស្គាល់ពីចម្ងាយស្រាប់ក៏ដោយ កិច្ចទាំងនេះត្រូវតែធ្វើជាអលជ្ជីដូច ទំនៀមទម្លាប់ ។ បើមិនធ្វើដូច្នេះទេ ពួកអ្នកយាមមានវាយគងច្រើន អន្លូងកាលណា ពួកទ័ពចោរក៏នឹងនាំគ្នាបាញ់ចំរុះពីក្នុងមកមិនយល់ថាគ្នា ឯងឬគ្នាគេឡើយ ។



សាកសួររួចហើយ ទើបស្នូរគងទីពីរបន្លឺឡើង ។ ក្នុងពេលនោះ រាហូហាមាត់បន្តិចម្តងៗ បើកច្រកឱ្យគ្នាគេចូលដោយសេរី ។ ស្នូរគងទីបី ជាសញ្ញាឱ្យកម្មករអ្នករវៃរ៉តបិទទ្វារមាត់រាហូវិញ ក្រោយដែលអ្នកយាម ឃើញថាពួកខ្លួនចូលគ្រប់គ្នាអស់ហើយ ។

ពួកចោរទាំងឡាយ ដែលនៅក្នុងជំរុំសំរាប់រក្សាមេធំនោះ រៀបខ្លួន តាំងពីស្នូរគងទីមួយ គឺរត់មកឈរទន្ទឹមគ្នានៅមាត់ទ្វារសាលដោយ មាន កាន់កាំភ្លើងប្រុងទៅតយុទ្ធផងក្រែងមានអាសន្នផ្សេងៗ ដែលនឹងទទួលខុស ត្រូវរៀងខ្លួន ។

វានាំលោកសុគន្ធានឹងបុត្រីចូលទៅក្នុងសាលកណ្តាលជំរុំដែលគេ និយមហៅថាគុហា. ឱ្យឈរចំពោះមុខមេចោរធំដែលអង្គុយលើកៅអី បង្អែកមួយខ្ពស់លាបទឹកមាសភ្លឺច្រាលដាក់ជើងគងលើតុមួយទាបជាងកៅអី នោះ ហើយក្រាលដោយព្រំធ្វើអំពីសូត្រលាយសែសយក្រឡៃមាស ។ នៅលើតុនោះគេរៀបគ្រឿងសក្ការៈដូចជាផ្កានឹងប្រទីបជាដើម ។ ស្ត្រី ក្រមុំពីររូបស្លៀកពាក់ដោយសំពត់អាវយ៉ាងថ្លៃថ្នូរ នឹងលំអដោយគ្រឿង អលង្ការគ្រប់មុខ ឈរអមសងខាងកាន់ផ្លិតមួយម្នាក់បក់ជូនព្រះតេជព្រះ-គុណមេចោរនេះ ។ កូនចោរទាំងឡាយសុទ្ធតែលុតជង្គង់-ក្រាបក្បាល ដល់ដី ហើយរក្សាសភាពស្ងប់ស្ងាត់ចាំទទួលបង្គាប់ ។

– នេះលោកចៅហ្វាយស្រុកឬ? (មេចោរនិយាយពេបមាត់ទៅ កាន់លោកសុគន្ធា ដែលជាប់ចំណងស្លាបសេកឈរនៅមុខវាសឹងពុំនឹង) លោកចៅហ្វាយស្រុក... ត្រួតរាស្ត្រក្នុងមួយនគរស្រុកខ្មែរបានហើយឬ?

...សុំឱ្យដឹងថា បើត្រូតអាណោត្រូតចុះ កុំតែមកត្រូតអញកូនចៅអញត្រូត



មិនបានទេគេមុនៗមកក៏មិនដូចលោកចៅហ្វាយឯង? លោកឯងមកស្ដីក៏បេះតែដើររាតត្បាតដល់ពួកអញម្ល៉េះ ? ចាប់ពួកអញដាក់គុក ? ហើយធ្វើបាបអាកញ្ចុះជាសេនាដៃស្ដាំអញខ្លាំងម្ល៉េះ ? វាដណ្ដឹងកូនលោកឯង



តាមស្រួលលោកឯងមិនព្រមឱ្យ លោកឯងចង់ទុកឱ្យអាណោទៀតផ្សេងវិញ? លោកឯងធ្វើការមិនសុចរិតយុត្តិធម៌ទេ ចោរលួចគោគេច្បាស់នឹងភ្នែក លោកឯងលែងចោរនោះទៅវិញ ទុកឱ្យម្ចាស់ទ្រព្យគេក្ដៅក្រហាយលុះសព្វថ្ងៃ បើជំរះមិនត្រឹមត្រូវយ៉ាងនេះទេ ត្រូវអញជំរះលោកឯងម្ដងវិញ..

– អ្នកឯងគ្មានអំណាចជំរះយើងទេ... (លោកសុគន្ធាតបដោយខំប្រឹង) ។

– ឯងគ្មានអំណាចឆ្លើយទេ ។

– យី ! អាកញ្ចុះមិនគួរក្បត់អញ... (ពាក្យនេះមិនបានចប់ទេ ដោយចោរម្នាក់ដែលឈរជិតលោក ទះមាត់លោកមួយដៃយ៉ាងខ្លាំង) ។

– អញប្រាប់ហើយ ថាមិនឱ្យឯងនិយាយតវ៉ាអ្វីឡើយនៅចំពោះមុខអញ បើឯងគ្រាន់បើណាស់ ចាំស្ដាប់អញកាត់ទោសតែម្ដងទៅចុះ រួចសឹមឯងចង់ឧទ្ធរណ៍ទៅណាក៏ទៅណាក៏ទៅចុះ...នាយពេជ្ឈឃាដ ?

– ប្របាទម្ចាស់ (កូនចោរម្នាក់ក្រោកឡើងឈរប្រណម្យឱនក្បាលចុះ) ។

– ចំពោះឈ្មោះសុគន្ធានេះ នាំវាទៅធ្វើទារុណកម្មដោយសំឡូតទៅ អាណិតវាព្រោះទើបនឹងខុសម្ដង ចំណែកកូនស្រីវាដែលគ្មានខុសអ្វីត្រូវទុក ធ្វើជាប្រពន្ធចុងអញ ឯនាយកញ្ចុះដែលមានសគុណនឹងយើងនោះអញតែង តាំងឱ្យឡើងជានាយសក្តិបីដើម្បីជារង្វាន់ដល់វា ។

– ប្របាទម្ចាស់សម្រេចនេះហៅសមណាស់ (ដោយកញ្ចុះញញឹមហើយថ្លែង) ខ្ញុំបាទអរគុណរកអ្វីផ្ទឹមពុំបាន ។

– អើ ! ឯងគ្រាន់បើជាមនុស្សស្មោះត្រង់នឹងអញ ពីថ្ងៃនេះទៅ អញបើកអំណោចឱ្យឯងគ្រប់មុខ មួយទៀតបើឯងចង់បានរង្វាន់អ្វី ក៏អញឱ្យដែរ ។

– សូមប្របាទម្ចាស់អត់ទោសឱ្យខ្ញុំបាទៗចង់បានមនុស្សទោសស្រីនេះទៅឱ្យធ្វើជាភរិយាកូនប្រុសខ្ញុំបាទ ហើយសុំមនុស្សសែសិបនាក់ ដើម្បីការពារនាងនេះឱ្យបានសម្រេចតាមបំណងខ្ញុំប្របាទ ។

ល្អ ! ល្អ ! ល្អ ! យកចុះ ! យកអ្វីយកចុះ !

ចោរសែសិបនាក់កាន់អាវុធគ្រប់ដៃ នាំនាងគន្ធពិដោចេញពីជំរុំតាមបញ្ជាការលោកសក្តិបីកញ្ចុះដើរកាត់ព្រៃតម្រង់ទៅទិសបូពិ។ ចំណែកកញ្ចុះម្នាក់ឯង ចេញមកលិចវិញសំដៅមាត់ដែល ទើបជួបនឹងពួកទ័ពរាជការដែលដោយគ្រាញ់នាំមករកដានចោរ ក៏វាប្រាប់ពួកទាហានថាពួកចោរហួសទៅខាងប្រាសាទកោះកែរ ដើម្បីបង្វែងដាន ។ ឯស្លាក-ស្នាមនៅនឹងកដៃវា វាបង្ហាញគេថា ចោរចងស្លាបសេកវានោះ គឺជាល្បិចរបស់វាដើម្បីកុំឱ្យគេសង្ស័យថាវាចូលដៃខាងចោរ ។ មុននឹងចេញមកដល់មាត់វាបានយកវល្លិ៍មករុំនឹងដៃវាឱ្យតឹងមួយស្របក់ទៅ. លុះស្រាយមកវិញ ស្នាមនោះមានក្រឡៃតនៅនឹងស្បែកដៃ ។

✳✳✳✳✳

✳✳✳

# ជំពូក១០

## នាយព្រួល

ពួកចោរភ្នំត្បែងនេះ បានដើរចាប់អ្នកស្រុកជាច្រើនដែលកំពុងរកស៊ីជុំកូនប្រពន្ធនៅផ្ទះសម្បែងគេ នាស្រុកខេត្តឆ្ងាយៗយកមកវាយដំធ្វើបាប។ បើមានបងប្អូនណាអង់អាចហើយហ៊ានមកជ្រែកកោនយកប្រាក់មកសុំលោះទៅ នោះនឹងបានរួចខ្លួនទៅវិញ ។ ចុះបើគ្មានគេលោះទេ អ្នកនោះមុខជានឹងរងទណ្ឌកម្មអកុសល នៅទីជំរុំចោរនេះលុះត្រាតែជីវិតបង់ ។ មិនតែពួករាស្ត្រទេ សូម្បីតែទាហានឬភ្នាក់ងារប៉ូលិសដែលបានចាញ់ដៃវាទាំងប៉ុន្មាន វានាំយកមកប្រើការដូចគោក្របីដែរ ។ កាលដែលចាប់លោកសុគន្ធាមកនេះ វាចាប់បានភ្នាក់ងារប៉ូលិសរបស់លោកច្រើនរូប យកមកឱ្យសោយទុក្ខដូចគ្នា ។ ព្រឹកឡើងថ្ងៃរះផុតចុងឈើពុំទាន់ទេ ទោះកំពុងចុះអ័ព្ទមើលគ្នាពុំស្គាល់ក៏ដោយគេឃើញមនុស្សកំសត់ទាំងនោះខ្លួនទទេ ស្លៀកតែខោខ្លីកន្ទើញៗ ដើរចេញពីជុំរុំតាមមាត់ទ្វាររាហូ ទន្ទឹមគ្នាបីៗ ឱបដៃខាំធ្មេញតស៊ូនឹងធាតុរងា ។ បណ្តើរពួកនេះសំដៅទៅព្រៃ ដើម្បីកាប់ឈើអារចាំងឈូសធ្វើជាគ្រឿងផ្ទះឬគ្រឿងប្រើប្រាស់ជាប្រយោជន៍ជំរុំ ។ ក្នុងការនេះ បើមានជនណាម្នាក់ដើរយឺតឬធ្វើអ្វីពុំរួចដោយអស់កំលាំងជននោះមុខជានឹងរងកម្មដោយរំពាត់ខ្សែតី ដែលពួកចោរវាយវាត់ទុកស្នាមឆ្នូតៗនៅខ្នងជាមិនខាន ។ មើលចុះកម្រណាស់ជនដែលគ្មានស្នាមរំពាត់នៅខ្លួន។

វាមិនប្រើសត្វពាហណៈទេ ព្រោះវាមានមនុស្សបរិបូណ៌ហើយ ។ វាចង់ប្រើប្រាស់ធ្វើអ្វីក៏បានទាំងអស់ ។ ចំណែកលោកសុគន្ធាវិញ គេទុកដូចជាលោកមានសំណាងជាងគេបន្តិច ព្រោះវាដាក់ទណ្ឌកម្មដោយសំឡូត គឺគ្មានវាយតក់អ្វីទេ ហើយមិនបណ្ដើរឱ្យធ្វើការដូចជនទាំងនោះផង ។ ប៉ុន្តែបើគេថ្លឹងមើលទៅ ឃើញថាមិនជាជាងគ្នាប៉ុន្មានឡើយ ។ គឺវាយកលោកទៅដាក់ឃ្នាងនៅក ខ្នោះនៅដៃ ច្រវាក់នៅជើងឱ្យអង្គុយនៅក្នុងបន្ទប់មួយតូចគ្មានបង្អួចសោះ ។ ពេលបាយវាយកបាយសាបមួយត្រឡោកដូងមកដាក់ឱ្យ ហើយវាដើរទៅបាត់ទៅ ទឹកក៏វាមិនយកមកឱ្យអាស្រ័យផង ។ ពេលមុនដំបូងលោកលេបបាយនេះមិនរួចទេ ប៉ុន្តែក្រោយមក ដោយហេតុក្រពះដែលគ្មានអាហារមួយគ្រាប់ណាចូលសោះ ស្រែកកញ្ជ្រោលខ្លាំងពេក ទើបលោកធ្មេចភ្នែកលេបបានបន្តិចបន្តួច ។ គ្មានញាតិនឹងមិត្តឯណាមកកំដរលោកឱ្យបាត់ទុក្ខព្រួយទេ លោកអង្គុយសម្រក់ទឹកភ្នែកតែម្នាក់ឯងកណ្ដាលហ្វូងចោរក្នុងព្រៃសមសាន្តស្រែកទឹកគ្មាននរណាយកទឹកមកឱ្យ ។ ឈឺដៃគ្មាននរណាគេមកព្យាបាលរបួសឱ្យសោះ ។ ឈឺខ្លួនចុកចាប់ពេញទាំងខ្លួនកាយ គ្មាននរណាមកគក់ច្របាច់ឱ្យទេ ចុះកម្មអ្វីក៏អាក្រក់ខ្លាំងម្ល៉េះ? ស្លាប់ប្រពន្ធ ស្លាប់អស់មួយពូជ នៅសល់កូនស្រីមួយ គេមកផ្ដាច់ពីដួងចិត្តទៅទៀត មិនដឹងជាវាយកទៅធ្វើបាបយ៉ាងណា ។

បំណាច់ស្លាប់ សុំឱ្យស្លាប់ដោយសន្តិភាពទៅចុះ តែភ័ព្វវាសនាមិនចង់ឱ្យលោកបានដូច្នោះសោះ រាល់ថ្ងៃរាល់ពេលមានមារតាមមកផ្ចាញ់មិនចេះឈប់ឈរ ។ ញឹកជាងគេគឺនាយព្រួលជាអ្នកជំនាញខាងវិទ្យុផ្សាយ



ដំណឹងរបស់ក្រុមចោរនាយនេះ ដោយមានសមត្ថភាពគួរសមហើយមានតែម្នាក់ឯងដែលចេះខាងមុខការតិកនិកនេះ ក៏មានអកប្បកិរិយាឆ្មើងកោងកាចហើយឫកធំ នឹងបានទទួលសក្ដិយសពីមេចោរមកពាក់ក្នុងពេលថ្មីៗនេះ បន្ទប់ធ្វើការរបស់វានៅបៀតនឹងគុកលោកសុគន្ធា ។ កាលបើវាមានពេលទំនេរម្ដងៗវាមិនដែលខានចូលមកក្នុងបន្ទប់លោកទេ ហើយនិយាយឡកឡឺយគ្រប់បែបគ្រប់យ៉ាងឱ្យគេខ្លាចអំណាចវា ។ អានេះហើយជាសេនាដៃឆ្វេងរបស់មេចោរធំវាចង់ធ្វើអ្វីក្នុងជំរំ ស្រេចនូវចិត្តវាទាំងអស់ ដែល ចុះពីសក្ដិបីកញ្ចុះមកមានតែសក្ដិពីរព្រួលវានេះហើយ ។

– ម្ដេចទៅព្រះតេជព្រះគុណចៅហ្វាយស្រុកសុគន្ធា (វាចំអក) ឈ្មោះសុគន្ធានេះ ប្រែថាស្ត្រីមានក្លិនល្អ លោកប្រហែលជាទាស់មកពីឈ្មោះទេដឹង បានជាខកខានហុតឈាមរាស្ត្រក្នុងប៉ុន្មានថ្ងៃនេះ ។ ខ្លួនស្អុយគគ្រុកម្ល៉េះៗ ខំទៅយកឈ្មោះយ៉ាងល្អមកដាក់ឱ្យតែលប់មាឌ ។

វាថារួចវាទះកំភ្លៀងលោកមួយដៃហើយដើរចេញទៅ តាំងពីថ្ងៃអង្គារដែលលោកសុគន្ធាទើបនឹងទៅដល់នោះ វាលេងរឿងនេះឱ្យស្គាល់ស្នាដៃភ្លាម ។ ពេលយប់វាឱ្យគេបណ្ដើរលោកទាំងខ្នោះច្រវាក់មកទីដំណេកវាដែលជាប់នឹងទីវិទ្យុ ហើយវាឱ្យលោកអង្គុយច្របាច់ជើងឱ្យវា ទំរាំតែមានការទៅទទួលដំណឹងដែលផ្សាយចេញពីវិទ្យុទទួលសំឡេងម្ដងៗ ។

– ព្រះតេជគុណចៅហ្វាយស្រុកឯងដឹងខ្លួនហើយឬនៅ ? (វាសួរលោក) ដែលអញហៅមកឱ្យច្របាច់ជើងឱ្យអញនេះ?

– លោកបើកអំណាចឱ្យខ្ញុំឆ្លើយទេ ? (លោកសុគន្ធាសួរវិញ)

– យី ! អញសួរហើយ ម្ដេចមិនចង់ឆ្លើយទេឬ ?

– បើលោកបើកអំណាចឱ្យខ្ញុំនិយាយហើយ ខ្ញុំអរណាស់សូមជ្រាបថា ដែលលោកឱ្យខ្ញុំមកប្រាប់ដើងជូនលោកនេះ ជាការថោកទាបដល់ខ្ញុំហើយ ប៉ុន្តែខ្ញុំមិនអាក់អន់ចិត្តអ្វីទេ បើបានលោកមេត្តាយកខ្ញុំមក ឱ្យប្រាប់ដើងជូនលោករាល់ថ្ងៃយ៉ាងនេះ ខ្ញុំរឹតតែអរគុណលោកច្រើនទៀត ។

– ម្ដេចក៏និយាយឯចឹង ? ហាៈ ! ហាៈ ! ចេះចំអកឱ្យអញ ផង ? ឯងស្គាល់ថ្នាំខ្លាំងទេ ?

– សូមលោកជ្រាបថា (លោកសុគន្ធាឆ្លើយ) ការថោកទាបនោះពិតណាស់ទៅហើយ ប៉ុន្តែខ្ញុំមិនគិតទេ ! ព្រោះខ្ញុំបានតាំងចិត្តថាការថោកទាបនោះ មានឡើងតែលើរូបជនណាម្នាក់ ដែលមានឋានៈខ្ពង់ខ្ពស់ ហើយទៅបំរើបាទជើងជនម្នាក់ទៀតដុនដាបជាងខ្លួនប៉ុណ្ណោះ ដូចកាលខ្ញុំ នៅក្នុងងារជាចៅហ្វាយស្រុកយល់ខុសទៅបំរើភ្នាក់ងារប៉ូលិសម្នាក់នោះ ថ្វី ក៏មិនថោកទាប ! តែឯរូបខ្ញុំក្នុងគ្រាឥឡូវនេះ គឺជាមនុស្សទោសគេទុកជា ឈ្លើយពេញទីទៅហើយ ខ្លាចអ្វីនឹងមកបំរើលោកជានាហ្មឺនសក្តិខ្ពស់ ! ខុសគ្នាឆ្ងាយណាស់លោករវាងខ្ញុំនឹងលោកពេលនេះ មិនគួរបើនឹងយកមក ប្រៀបប្រដូចដូច្នេះបាន ។ មួយទៀតខ្ញុំនឹកសប្បាយចិត្ត ដែលមកជ្រកកោនក្រោមបុណ្យលោកផង ព្រោះខ្ញុំបានសង្កេតឃើញថាលោកកាចមែន ហើយមាត់អាក្រក់មែន ប៉ុន្តែចិត្តល្អប្រពៃណាស់ ក្នុងជំរុំនេះខ្ញុំនឹងរកជន ណាម្នាក់ឱ្យមានចិត្តល្អដូចលោកគ្មានសោះ ។



មែន ! លោកសុគន្ធាបានសង្កេតនូវអកប្បកិរិយានឹងសំដីសំដៅទៅឃើញថា នាយព្រួយចិត្តថ្លើមមិនជាអាក្រក់ទេ ប៉ុន្តែជាមនុស្សឆ្មើងបុណ្យបន្តិច វាធ្វើការអ្វីនីមួយៗសុទ្ធតែចង់ឱ្យគេកោតសរសើរ ហើយមិនសុខចិត្តយល់ព្រមនៅពីក្រោមនរណា ។ កាលបើឮលោកនិយាយដូច្នេះ ហើយវាញញឹមមិនបញ្ចេញវាចាថាដូចម្ដេចឡើយ បានមួយសន្ទុះក៏និទ្រាលក់ទៅ ។ អតីតមន្ត្រីកាន់អំណាច អង្គុយបក់មូសឱ្យវាលុះត្រាតែវាចុះពីគ្រែទៅទទួលដំណឹងពីវិទ្យុម្ដងៗទើបឈប់សំរាកដៃ ។ ពួកភ្នាក់ងារចោរដែលឈរយាមលោកនៅបៀតគ្រែនោះ ទៅជាធុញទ្រាន់ ហើយលើកកាំភ្លើងឡើងលីលើស្មាដើរចេញទៅឈរជក់បារីលេងនៅក្រៅបន្ទប់ធ្វើព្រងើយព្រោះទុកចិត្តថាមនុស្សទោសរបស់ខ្លួន មិនងាយនឹងរត់ទៅណាបានទេ ។ ក្នុងយប់នោះរាល់ៗដង នៅពេលដែលនាយព្រួលដេកលក់ទៅ ហើយជួនមានសូរសញ្ញាវិទ្យុហៅមកដោយនាយព្រួលពុំដឹងខ្លួននោះ វាបានលោកសុគន្ធានេះហើយ ដែលដាស់វាប្រាប់អំពីសូរសញ្ញាហៅនេះ លោកខំធ្វើឱ្យចោររូបនេះទុកចិត្តហើយអាណិតអាសូរណាស់ ក្រែងលោបានរណ្ដោះអំពីកម្មវេទនាខ្លះ នឹកថា ម្ដេចម្ដាក៏បានជនម្នាក់គ្រាន់និយាយទៅមករកខ្លួនដែរ កុំឱ្យខ្លួននៅធ្មឹងដូចខ្មោចស្លាប់ ។ ក្រៅពីនេះលោកគ្មានឃើញផ្លូវណានឹងរំពឹងឡើយ ។

លុះអង្គុយប្រចាំដើងនឹងបក់មូសឱ្យវា តែម្នាក់ឯងជ្រុលក្នុងរាត្រីហួសឆ្ងាយទៅ សភាពអស់កំលាំងនឹងស្រេកឃ្លាន បណ្ដាលឱ្យលោកទន់ត្របកភ្នែកចង់តែផ្ដេកខ្លួនទៅនិទ្រាដែរ ។ ប៉ុន្តែទើបនឹងងោកសំយុងក្បាល

ចុះទៅបន្តិចក៏មានសូរមួយរកថាជាសូរអ្វីពុំបាន មកបន្ទីនៅត្រចៀកលោក
ក៏ភ្ញាក់ខ្លួនឡើងមើលទៅមុខ ស្រាប់តែឃើញមានពស់មួយយ៉ាងធំពុំដឹ
មកដល់ពីកាលណាបើកពពារសំដៅទៅរកនាយព្រួលដែលកំពុងលក់ពុំដឹង
ខ្លួន ។

លោកកន្ត្រាក់បានបង្គោលមុងវាយពស់នោះស្លាប់ទៅ ។ នាយព្រួ
ឮសូរព្រួសប្រះ បើកភ្នែកឡើងមើលហើយឆ្ងល់

– លោក ! មិនអីទេ សំរាន្តទៅ (សុគន្ធាប្រាប់) ខ្ញុំវាយវាស្លា
ហើយ...

– អុះ ! ពស់នេះតិតចឹកខ្ញុំ ? (នាយព្រួលស្ទុះក្រោកអង្គុយឡើ





ក្បាលងាកទៅមើលអសុភសត្វ ភ្លេចទាំងធ្វើឫកក្រអឺតនឹងប្រើពាក្យថ្លៃថ្នូ)
យឺះ ! ប៊ីះសោះ កុំអីមិនងាប់ទេហ្អឹង !

នាយព្រួលទាញយកឈើទៅវាយសត្វនោះថែមទៀតហើយឆ្កឹះ
ត្រវែងចោលទៅក្រៅទៅ រួចវិលមកប្រាស់និន្ទ្រាតទៅទៀត ។

ស្អែកឡើងថ្ងៃពុធ ថ្វីបើដៃជើងនឹងកនៅតែជាប់ច្រវាក់ខ្នោះឃ្នាង
ដដែលនោះ លោកសុគន្ធាឃើញបានត្រជាក់ចិត្តមួយភាគរយហើយ ។

នៅថ្ងៃនេះវាឱ្យបាយបានក្រែលបន្តិចហើយរោយអំបិលឱ្យប្រៃឡមៗ
ផងឯនាយព្រួលមកអើតមើលលោកតែបន្តិចទេ អន់ញឹកញាប់ជាងពីម្សិល
ហើយវាគ្មាននិយាយស្តីអ្វីសោះវាគ្រាន់តែមើលត្រួតទីកន្លែងបន្តិចបន្តួចក៏
ដើរចេញទៅ ការវាមកត្រួតនេះគឺជាមុខការវាដែលត្រូវធ្វើរាល់ពេល ព្រោះ
វាជំនួសមេធំសំរាប់ការខុសត្រូវក្នុងជំរុំ ហើយមិនមែនមើលតែគុក លោក
សុគន្ធានេះទេ វាដើរមើលសព្វទីកន្លែងព្រមទាំងទៅមើលការងារ ដែលពួក
ឈ្លើយធ្វើក្នុងព្រៃផង ។

ឯនាយកញ្ចុះនោះ គេជាអ្នកជំនាញខាងនយោបាយនឹងការចំបាំង
សព្វសារពើ ។ តាំងពីគេបានសក្តិពាក់មកគេទៅណាមកណាសុទ្ធតែក្នុង
ឋានៈជាមេចោរធំ ហើយគេត្រួតពលចោរគ្រប់កងផង ។

នៅរសៀលថ្ងៃនោះ នាយព្រួលបានឱ្យគេដោះឃ្នាងនឹងខ្នោះចេញ
ពីលោកសុគន្ធា ទុកតែច្រវាក់ជើងបណ្តើរមកមន្ទីរខ្លួនធ្វើការហើយឱ្យលោក
ជួយបោសច្រាសគ្រឿងវិទ្យុខ្លះ ។ ក្នុងពេលនេះហើយដែលលោកសុគន្ធា
សំគាល់ឃើញថា នាយព្រួលប្រែអកប្បកិរិយាជាងដើមច្រើន វាចេះមក

អង្គុយនិយាយលេងនឹងលោកពីនេះពីនោះ លែងប្រើពាក្យអញ ឯងទៅ លោកសោះតែម្តង មានហុចបារីឱ្យលោកជក់ដែរ ហើយវា មើលរ នៅដៃលោក ឃើញហើយក៏រត់ទៅយកសំពត់នឹងថ្នាំមកលាប ហើ ឱ្យលោក ។ ប៉ុន្តែវាធ្វើយ៉ាងនេះមិនហ៊ានឱ្យពួកចោរណាម្នាក់ភ្នាវា សោះឡើយ វាបានប្រើពួកអ្នកយាមឱ្យទៅឈរនៅទីឆ្ងាយអស់ ។

– គិតទៅ ! មកនៅក្នុងព្រៃនេះយូរឆ្នាំណាស់មកហើយ (នា ព្រួលពោលដោយមិនភ្លេចគ្រវីក្បាលជាដំបូង) កូនប្រពន្ធនៅផ្ទះមិនដឹង យ៉ាងណាទេ ។

– លោកពីដើមនៅស្រុកណាទៅ ? (លោកសុគន្ធាសួរ)

– នៅព្រៃវែងឯណោះទេ ប៉ុន្តែ...ហ៊ឹ ! កុំសួរត្រង់នេះ...

តែផុតពាក្យ ក៏មានសូរសញ្ញាហៅវាឱ្យទៅកាន់វិទ្យុវាស្តាប់មួ សន្ទុះ ក៏ស្រែកសួរខ្លាំងៗទៅវិញថា «ទៅខាងណា? ....អ៊ីចាំមួយភ្លែត» វាក៏រត់ចេញពីបន្ទប់សំដៅទៅទ្វារក្រោយនៃគុហាកណ្តាលជំរុំដែលជាទីស្នាក់ អាស្រ័យរបស់មេចោរធំ មិនយូរប៉ុន្មាន ក៏រត់មកវិញស្រែកដាក់វិទ្យុទៅ ទៀតថា «លោកថាកុំឱ្យភ័យ មិនមែនមកចំយើងទេ ប៉ុន្តែត្រូវកុំប្រហែ ដើរចោលប៉ុស្តិ៍ណា: !» ។

– មិនដឹងជាយ៉ាងណាទេ (វាពោលប្រាប់លោកសុគន្ធា) ដំណើ ជាញឹកញាប់ថាព្រះករុណាទ្រង់មានរៀបចំទ័ពដើរធ្វើប្រតិបត្តិការកំចាត់ពួក ចោរព្រៃសម្បើមណាស់លោតែមកចំទីនេះឬអ្វីកូនប្រពន្ធខ្ញុំទៀតប្រហែល ជានឹងលែងឃើញមុខខ្ញុំហើយ ។



– មិនអីទេលោក (លោកសុគន្ធាតប) មនុស្សយើងម្នាក់ៗសុទ្ធ តែមានទេវតារក្សា ហើយបើនឹងមានគ្រោះថ្នាក់មកបៀតបៀនម្តងៗ នោះ គឺមកតែអំពីផលកម្មយើងពីអតីតជាតិប៉ុណ្ណោះ ប៉ុន្តែក្នុងជាតិនេះបើជាយើង ធ្វើល្អ គង់តែនឹងបានល្អទេ ដូចលោកដែលមានចិត្តល្អនេះ ទេវតាលោក មិនលក់ឡើយ ។

– លោកថាខ្ញុំល្អ ! លោកមិនដឹងថាខ្ញុំមានឈ្មោះជាចោរព្រៃពេញ ទីទេឬ ?

– លោកហៅតែមានឈ្មោះថាចោរព្រៃមែន ប៉ុន្តែមានឈ្មោះ នោះតែសំបកក្រៅទេ មានជាអ្វី ? ទេវតាលោកមើលតែចិត្ត បើចិត្តល្អ កាន់ធម៌សប្បុរសហើយ ទុកជាដូចម្តេចក៏នឹងបានគ្រាន់បើដែរ ។

នាយព្រួលគ្រាន់តែធ្វើមាត់ញឹមៗគ្មានតបថាដូចម្តេចទេ ។ ពេល យប់វាឱ្យលោកសុគន្ធា នៅអង្គុយគ្រាន់តែបក់មូសឱ្យវាប៉ុណ្ណោះ ។ វា គ្មានឱ្យច្រវាក់ជើងទេ មុននឹងនិទ្រាលក់ទៅវាផ្តាំនឹងលោកថាបើមានសូរ សញ្ញាវិទ្យុហៅវា សុំឱ្យលោកដាស់វាផង ។ លោកចាំយូរណាស់មិនឮ សូរសញ្ញាអ្វីហៅលោកសោះ ។ លុះពេលម៉ោងប្រហែលជាង៩អស់ មនុស្សសត្វទាំងឡាយសម្ងំសំរាកសំរាន្តគ្រប់គ្នា លោកនឹកឃើញថា បើ ជាទុកឱ្យពួកចោរឃុំឃាំងលោកតែយ៉ាងនេះរហូតទៅ លោកមិនទៅជា ពលរដ្ឋមួយឥតប្រយោជន៍ដល់ប្រទេសដូចជាគាកអំពៅគេចោលនៅក្នុងធុង សំរាមទៅហើយ ? គេថាស៊ូស្លាប់ជាខ្មោចទៅជាជាង បំណាច់រស់ជា មនុស្សហើយ ត្រូវរស់ឱ្យបានផលខ្លះដល់មាតុភូមិ មានកំលាំងបន្តិចបន្តួច

គួរតែបូជាថ្វាយមាតុភូមិ ទើបហៅជាមនុស្សពេញលក្ខណៈ ។ លោកនឹក
ថាបើជាភៀសខ្លួនរត់ទៅ លោករត់មិនរួចទេដោយជើងជាប់ច្រវាក់ ហើយ
គ្មានកំលាំងធ្វូនល្មមក្នុងការនេះសោះ មួយទៀតគ្នាគេច្រើនណាស់ យាម
នៅគ្រប់ទិសដំបន់ តើលោកត្រូវធ្វើម្ដេច? លោកអង្គុយគិតមួយសន្ទុះ
ឃើញឱកាសហុចឱ្យស្រួល លោកក៏លើកច្រវាក់ជើងឱ្យផុតពីដីកុំឱ្យឮសូរ
ហើយលបអង្អិលខ្លួនបន្តិចម្ដងៗ ចូលទៅជិតវិទ្យុហើយមួលខ្ទៅ នឹងធ្វើ
កិច្ចការតាមដែលលោកបានចំណាំឃើញនាយព្រួលធ្លាប់ធ្វើមកនោះ ។





លោកប្រថុយស្រែកដាក់ថា «អាឡូ ! អាឡូ ! មានជំរុំចោរធំនៅភ្នំត្បែង
មានជំរុំចោរធំនៅភ្នំត្បែង ! នាំទ័ពមកវាយ ! នាំទ័ពមកវាយ ! » ។

កំពុងនិយាយយ៉ាងនេះស្រាប់តែលេចនាយកញ្ចុះចូលមកតាមមាត់ទ្វារ ដោយបានស្ដាប់ឮសព្វគ្រប់ជាមុន ។ វាផ្ទុកញ្ញែឆ្វេកហៅពួកអ្នកយាមទាំងឡាយឱ្យមកចាប់លោកសុគន្ធាទៅឱ្យមេចោរធំ ចំណែកវាមានសក្តិពាក់ជាមន្ត្រីធំហើយវាមិនត្រូវចាប់ដោយខ្លួនឯងឡើយ ។ ក្នុងពេលតែបន្តិចដែលសល់នេះ គឺទំរាំពួកអ្នកយាមរត់មកដល់ លោកសុគន្ធាឆ្លៀតស្រែកថែមក្នុងវិទ្យុថា «ជួយផង ! សុគន្ធា !...ជួយផងសុគន្ធា !...» គឺសំឡេងនេះហើយដែលទៅចូលត្រចៀកលោកអធិការប៉ូលិសជាតិសារីណ្យនៅឯភ្នំពេញ កាលក្នុងយប់ថ្ងៃពុធក្រោយពីព្រឹត្តិការណ៍ចំនួនពីរថ្ងៃ ។

ក្នុងយប់នោះជំរុំទាំងមូលភ្ញាក់ឡើងហើយមានសកម្មភាពដូចពេលថ្ងៃ ។ មេចោរធំឡើងលើកៅអីខ្ពស់ជំរះការគ្មានបង្អង់វាបើកភ្នែកធំៗមើលលោកសុគន្ធា ដែលគេនាំយកមកឱ្យឈរនៅចំពោះមុខវា ។

– អញដាក់ទោសស្រាលឱ្យ ! ឯងពុំចង់ ! អាចោលម្សៀត (វាស្ដីឱ្យ) ឯងនេះទោសត្រូវប្រហារជីវិតបង់ ប៉ុន្តែនឹងសម្លាប់ឯងភ្លាមៗទៅ គេនឹងយកតម្រាប់តាមឯងដោយងាយនៃពេជ្ឈឃាដ ! ឯងយកអាសត្វនេះទៅធ្វើទារុណកម្មជាទម្ងន់ចំនួនបីថ្ងៃបីយប់ រួចសឹមសម្លាប់វាដោយចងកព្យួរនៅមុខជនានុជននៅថ្ងៃបន្ទាប់ពីនោះ ។

– ការនេះខូចមកពីសក្តិ២ព្រួល ជាអ្នកសំគំនិត (នាយកញ្ចុះខ្សឹបប្រាប់មេចោរធំ) មនុស្សទោសដាក់គុកសុខៗ វាឱ្យគេនាំយកទៅក្នុងបន្ទប់

វា នឹងអាលបញ្ចុកបន្សីរួចបង្ហាញផ្លូវឱ្យក្បត់ក្រុមយើង វានេះគឺជាអាក្បត់ពេញទី វាឱ្យហៅរាជការមកវាយកំទេចយើងហើយ ទុកវាធ្វើអ្វីទៀតមនុស្សក្បត់យ៉ាងនេះ ។

– ល្អ ! ល្អ ! ល្អ ! អាកញ្ចុះឯងនិយាយត្រូវ ! ទុកធ្វើអ្វីអាមនុស្សក្បត់ ! នែពេជ្ឈឃាដ ទៅហៅអាព្រួលមកឱ្យអញជាប្រញាប់ ។

បន្តិចនាយព្រួលចូលមក

– យើ ! អាក្បត់ (មេចោរហៅនាយព្រួលដែលមកដល់មិនបានបងរង់ជើង) ឯងដល់ម្ល៉ឹង ? ប៉ុនមនុស្សអញឱ្យដាក់គុកល្ងិតបាយសាបឯងហ៊ានយកទៅបញ្ចុកបន្សីហើយបើកឱ្យវាក្បត់អញ !

– ទានប្រោសខ្ញុំបាទ.... (នាយព្រួលទើបនឹងហើបមាត់បានបន្តិចមេចោរក៏និយាយកាត់) ។

– អុះ ! ឯងស្មានថាអញបើកឱ្យឯងឆ្លើយឬ ? នែពេជ្ឈឃាដបកសក្តិអានេះ ហើយយកវាទៅបាញ់ចោលភ្លាម ព្រោះវាទើបនឹងធ្វើខុសម្តង ។

ពេជ្ឈឃាដនាំនាយព្រួលទៅបាត់មួយសន្ទុះទៅហើយ តែមេចោរក៏មិនព្រមចាត់ការដូចម្តេចតទៅទៀត សុខចិត្តតែពីអង្គុយចាំលុះត្រាតែឮសូរកាំភ្លើងរបស់បំរើខ្លួនបន្លឺមកដល់ត្រចៀកទើបសុខចិត្តដកខ្លួនចេញទៅរកដំណេក ។

*****

# ជំពូក១១

## ទារុណកម្ម

មេចោរព្រៃបានសំរេចសេចក្តីគ្មានពិចារណាហើយ តាំងពីយប់នោះមកវិទ្យុទុកចោលទំនេរ គ្មាននរណាចាំទទួលដំណឹងឬផ្សាយបញ្ជាការឱ្យមានទាក់ប្រស្រ័យនឹងក្រុមចោរតូចតាច ដែលនៅក្រោមបង្គាប់មេចោរធំនេះយ៉ាងម្តេចសោះ ។ អត់ពីនាយព្រួលទៅ ក្នុងជំរុំទាំងមូលនឹងរកអ្នកជំនាញណាម្នាក់មកជំនួសក៏គ្មាន ហើយគ្មានអ្នកណាឈឺឆ្អាលដើម្បីឱ្យមានសកម្មភាពក្នុងការនេះផង ។ ប៉ុន្តែការទាំងនេះវាពុំគិតទេវាររវល់តែឈ្ងុយឆ្ងាញ់ក្នុងការសម្រេកឈាមនៃមនុស្សសុចរិតឯណោះវិញ ។ ក្នុងមួយថ្ងៃៗបើមិនបានលោហិតមួយដំណក់លាបព្រះធរណីឱ្យក្រហមទេ វានឹងបរិភោគបាយមិនចូលឡើយ មិនថាតែមេចោរទេ សូម្បីតែកូនចោរក៏ដូច្នេះដែរ ។ កាលបើឮមេវាកាត់ទោសប្រហារជីវិតលោកសុគន្ធានេះរួចភ្លាម វានាំគ្នាហ៊ោកញ្ជ្រៀវអបអរខ្លាំងណាស់ សមបានឮថាឱ្យធ្វើបាបលោកក្នុងបីថ្ងៃបីយប់មុននឹងសម្លាប់ជាផ្តាច់ព្រាត់ផង វាប៉ងក្នុងចិត្តតែរាល់រូបថានៅថ្ងៃស្អែកខានស្អែកនេះ វានឹងបានឃើញឱ្យពេញភ្នែក នូវទស្សនីយភាពមួយដ៏ ឧឡារិកដូចបានធ្លាប់ឃើញពីថ្ងៃមុនជាមិនខាន ។ គេបានជំនុំគ្នាធ្វើកម្មវិធីទុកជាស្រេចសំរាប់បីថ្ងៃ ឱ្យបានសមសក្តិលោកចៅហ្វាយស្រុក ដូចគេបាននឹកភ្លកមកពីថ្ងៃមុន ។

ដើម្បីនឹងចាប់ផ្តើមការសំរេចកម្មវិធីនេះ ពេលព្រឹកឡើងពុំទាន់
ច្បាស់ផង អ្នកយាមប៉មទាំងបួនជ្រុង វាយគងឆ្លើយឆ្លងគ្នាដើម្បីហៅអ្ន
ស្រុកភូមិទាំងឡាយមកជួបជុំនៅមុខជំរុំ ព្រមទាំងដាស់ពួកក្រុមចោរខ្ញ
ប្រុងប្រៀបរៀបចំប្រដាប់ប្រដា ។ កន្លះម៉ោងក្រោយមក បណ្ដាជ
ដែលមកកកកុញនៅទីវាលមុខជំរុំនោះ ចោលភ្នែកទាំងអស់គ្នាចំទ្វារ
ហាក់ដូចជាមើលទៅឆាកល្ខោនដែលនឹងបើកវាំងននបញ្ចេញរបាំ ។ ទ្វា
វាហ្វូបើកបន្តិចម្តង១តាមសង្វាក់ស្គរឆៃយ៉ាំដែលបន្លឺពីក្នុងមក ។ បើកបា
ធំស្រឡះពេលណាពួកកូនចោរធាកហ៊ោបីដង រួចក៏កាន់លំពែងនឹងខែល
រត់ស្រចេញមក វាទទីឱ្យបានដីស្រឡះរាងមូលស្មោះហើយធំទូលាយ វា
ឈរនៅតាមជាយទីលាននោះ ធ្វើជារបងឃាត់អ្នកស្រុកកុំឱ្យចូលលាយឡ
នឹងពួកនាម៉ឺនចោរដែលចេញមក បន្ទាប់ពីនោះវាដង្ហែមេចោរធំមកឈរ
នៅចំហៀងខាងឆ្វេង ហើយចុងក្រោយបំផុតត្រូវវេនលោកសុគន្ធាចេញ
មកដោយមានភ្លេងឆៃយ៉ាំជូនពីក្រោយ ។ បើជារឿងល្ខោនលេងក្នុងរោង
វិញ លោកសុគន្ធានេះត្រូវតែងខ្លួនយ៉ាងសង្ហា អង្គុយលើគ្រែស្នែងមានគេ
បាំងក្លស់ឱ្យផង ។ ព្រោះលោកជាតួឯកតែមួយក្នុងរឿង ។ ប៉ុន្តែស្ដាយ
ពេករឿងនេះមិនមែនជារឿងល្ខោនហើយ ឆាកនេះមិនមែននៅក្នុងរោង
ល្ខោនសោះ ។ ក្នុងពេលនោះ បើសិនជាមានជនប្រកបដោយធម៌សប្បុរស
មេត្តាករុណានៅលាយជាមួយនឹងបណ្ដាអ្នកមើលផង ប្រហែលជាជននោះ
នឹងដកខ្លួនថយចេញទៅទីឆ្ងាយអង្គុយជូតទឹកភ្នែកតែឯងទៅហើយ ។
មើលចុះតួឯកនោះ ខ្លួនទទេមានតែឆរឹងជនីប្រាង ពោះផតដូចជាគ្មានអ្វី



នៅក្នុងក្រពះសោះដៃជើងស្គមរកសាច់មួយដុំគ្មាន ដើរចេញមកទទ្រេត ទទ្រោតទប់តែអាត្មាសឹងពុំជាប់ផង ។ ចង្រៃមានជាប់ច្រវាក់នៅជើងខ្ទោះនៅដៃ នឹងឃ្នាងនៅកទៀត ? លោកដើរមួយជំហាន១ដោយខំអស់ ទំហឹងថែមទាំងវារុញច្រានផងទៀត ដើម្បីឱ្យឆាប់បានទៅដល់គោល បំណងរបស់វា ។ នៅចំកណ្ដាលទីលានគេដោតបង្គោលឈើមួយធំប៉ុន ភ្លៅដែលមានមែកបន្តិចនៅចុងគឺនៅនឹងបង្គោលនេះហើយ ដែលពួកចោរវាយកទុក្ករជនមកចងដៃព្យួរទៅនឹងមែកខាងចុងសំយុងជើងមកដី។ ពួកឈ្លើយទាំងឡាយរបស់ក្រុមចោរ ដែលត្រូវទៅធ្វើការក្នុងព្រៃតាំងពី ព្រឹកនោះបានច្បាប់ឈប់សំរាកមួយពេល ដើម្បីនៅមើលទារុណកម្មជាគំរូ។ កូនចោរម្នាក់ចូលមកលុតជង្គង់ទទួលយកលិខិតមួយច្បាប់ពីមេចោរធំទៅ ឡើងលើជើងម៉ាខ្ពស់មើលស្រែកប្រកាសអំពីកំហុសរបស់លោកសុគន្ធា ប្រាប់គ្រប់គ្នាហើយហាមកុំឱ្យពួកកូនចោរក្បត់ក្រុមខ្លួន ព្រមទាំងកុំឱ្យពួកឈ្លើយមានគំនិតខ្មៅចង់រត់លួនឬចង់តដៃនឹងពួកវាឱ្យសោះ ប្រកាសរួចហើយ មានពួកវាម្នាក់មាឌមាំកាន់រំពាត់ខ្សែតីវែងចេញមកបង្ហាញខ្លួន ដោយភ្នែកចោលមកមើលដៃមេវាដែលនឹងធ្វើសញ្ញាផ្សេង១ឱ្យ ។

កាលបើមេចោរធំ ញោចដៃម្ដងនាយនេះវ៉ៃខ្សែតីមួយខ្វាប់មកលើមនុស្សជាប់ចំណង ទុកស្នាមមួយក្រហមច្រាលលើស្បែកសនៃជននោះ។ វាវាយរបៀបនេះ លុះត្រាតែគ្រប់ហាសិបរំពាត់ ទើបមេចោរ ធំលែងញោចដៃ ។ បានរសាយពីចំណោងដៃហើយ បុរសអកុសលទន់ ជើងដួលទៅដីធ្មេចភ្នែកភ្លឹស១ ពួកចោរយកទឹកមួយបំពង់មកជះចំកណ្ដាលមុខ ហើយចាប់

លើកទុក្ករជនឡើង បណ្ដើរទៅទីការដ្ឋានក្នុងព្រៃជាមួយ នឹងពួកឈ្លើយ នៅពេលដែលមេចោរធំនឹងពួកមន្ត្រីចោរចូលទៅជំរុំវិញ ។

នៅក្នុងព្រៃទុក្ខទោសរបស់អតីតចៅហ្វាយស្រុក ទ្វេមួយជាប្រាំ ។ សព្វមួយដងឈើមួយដើមគេតម្រូវឱ្យមនុស្សប្រាំនាក់ធ្វើការ ដល់មកថ្ងៃនេះគេដាក់ឱ្យមនុស្សទោសថ្មីធ្វើតែម្នាក់ឯង ធ្វើមិនរួចគេវាយទះឈាមដែលពីមុនគ្រាន់តែដាម១ទៅតាមឆ្នូតខ្សែតី ឥឡូវនេះជិតសុះពេញតែខ្លួន ។ ស្បែកសប្រែទៅជាស្បែកក្រហមវិញ ។ ក្នុងមួយថ្ងៃនេះ ជនកំសត់ដួលរកកលនឹងសន្លប់បួនប្រាំដង តែវេទនាយ៉ាងណាទេ ? ក្នុងរដូវរងាយ៉ាងនេះផង មនុស្សយើងរាល់រូបគ្រាន់តែដើរទង្គិចបន្តិចបន្តួចប៉ុណ្ណោះ ស្រែកអែយ៉ូយអែយ៉ៃទៅហើយ កំលាំងបើត្រូវគេវាយដោយពេញទំហឹងទុកស្លាកស្នាមឱ្យទៀត...ឱ ! លោកសុគន្ធា ! ក្លិនក្រអូបរបស់លោកទៅណាបាត់ទៅ ក៏ពួកមនុស្សទុច្ចរិតគ្មានជំឬអើពើបន្តិចសោះ ? គុណសម្បត្តិលោកដែលខំធ្វើលរកាន់សុចរិតនឹងយុត្តិធម៌មកយូរអង្វែងឆ្នាំហើយតើសាបរលាបទៅហើយឬក៏មិនឃើញបានលទ្ធផលអ្វីសោះ ? ឬមួយក៏ទារុណកម្មនេះហើយជាលទ្ធផលនៃអំពើល្អទាំងនោះ ? កាលនាយព្រួលនៅ លោកគ្រាន់មានរំពឹងលើវាខ្លះ ! ទោះវាកាចជាយ៉ាងណាគង់វាមានទឹកចិត្តបន្តិចបន្តួច បង្ហាញថាវាអាចដឹងខុសត្រូវដែរ រំពឹងថាថ្ងៃក្រោយគង់នឹងបានវាជាមិត្តភក្តិត្រឹមត្រូវ ។ ចុះបើជនរូបនេះ គេប្រើពេជ្ឈឃាដថាឱ្យយកទៅសម្លាប់ទៅហើយតើរំពឹងនរណា ? ណ្ហើយចុះលោក ! គេថាឪអត្តាហិអត្តនោនាថោឱ ខ្លួនត្រូវតែទីពឹងខ្លួន ខំប្រឹងទៅ ! ខំប្រឹង ទៅ !



ខំប្រមូលកំលាំងទាំងប៉ុន្មានដែលសេសសល់ក្នុងកាយយកមកតស៊ូ ទៅអស់សង្ខារថ្ងៃណាសឹមឈប់ !

ក្នុងពេលដែលលោកសុគន្ធាដួលទៅដីម្ដង១ ហើយពួកចោរវាយដំប្រំធាក់បន្ថែមគួរឱ្យវេទនានឹងភ្ញាក់ណាស់នោះ ពួកឈ្លើយឯទៀត ទោះត្រូវជាអ្នកក្រោមបង្គាប់លោកពីដើមឬពុំដែលស្គាល់លោកសោះក៏ដោយចំនួនប្រហែលជាងហាសិបនាក់ខំអត់ទ្រាំមើលនូវទស្សនីយភាពអកុសលនេះពុំបាន ក៏ដើរទាំងច្រវាក់នៅជើង កាន់ចពូថៅឬប្រដាប់ប្រដាធ្វើការនៅដៃចូលសំដៅទៅពួកចោរកំណាចទាំងនោះ ហើយតិតនឹងតស៊ូដណ្ដើមយកសេរីភាពលោកសុគន្ធានឹងសេរីភាពរបស់រៀងខ្លួនមកវិញ ។ ប៉ុន្តែបំណងនេះពុំបានសំរេចដូចប្រាថ្នាទេ ។ ព្រោះគ្នាតិចកាន់តែចបនឹងពូថៅធ្វើម្ដេចនឹងបានឈ្នះគេដែលមានគ្នាច្រើន កាន់កាំភ្លើងគ្រប់ដៃ ។

ម្ល៉ោះហើយមានតែទោសទុក្ខទេដែលជាលទ្ធផលនៃការរបះរបោរទាំងនេះ ហើយភ្លើងឆេះក្នុងទ្រូងនៃជនដែលគេបង្ក្រាបលើ ក៏រឹតតែឆេះឡើងមិនអាចរលត់ទៅវិញបានឡើយ ។

ថ្ងៃបន្ទាប់១មកទៀត ទស្សនីយភាពដែលមានមកនេះមិនខុសពីគ្នាប៉ុន្មានទេ ។ ធ្មេញដង្កាប់នៃជនកំណាចរិតបន្តិចម្ដង១ជាលំដាប់ គិតធ្វើម្ដេចឱ្យតែអ្នករងអំពើ ទទួលមហាទុក្ខវេទនាបានយូរអង្វែងមុនផុតជីវិត ។

*****

# ជំពូក១២

## មីង_សុខ

លោកសាវ័ណ្យនឹងដោយក្រាញ់នៅមិនឆ្ងាយប៉ុន្មានពីទីជំរុំពួកចោរទាំងនោះទេ ។ ឯការរបស់គេដែលគូសទុកក្នុងខ្លួននោះគឺ បើស៊ើបទៅដឹងថាវានៅទីកន្លែងណាឱ្យច្បាស់ គេនឹងត្រឡប់ទៅទីរួមខេត្តវិញ ចាត់ការសុំទ័ពរាជការមកវាយកំទេចជាមិនខាន ។ តែមានចិត្តមួយនឹកភ្នកមករាំងរាមិនឱ្យផែនការនេះសំរេចទៅបាន តែនឹកថាបើជាធ្វើបែបនេះទៅ នោះជីវិតលោកសុគន្ធាមិនធ្លាក់ទៅក្នុងគ្រោះថ្នាក់ទៅហើយ ? ចុះកូនក្រមុំលោកដែលជានុយមួយធំក្នុងការស្វែងរករបស់អធិការនេះដែរ នឹងទៅជាយ៉ាងណាទៅ ? ។ អ្នកទាំងពីរកំពុងខ្វល់ខ្វាយដោយមិនដឹងគិតដើរផ្លូវណាឱ្យបានសំរេចដូចប្រាថ្នាសមតាំងពីមុនពេលបាយថ្ងៃត្រង់មកដល់ពេលព្រលប់យប់ផុតទៅទៀត អ្នកទាំងនេះជាប់រវល់មើលរបួសកូនមីងសុខគ្មានឈប់ដៃផង ។ ឯគំនិតថាចង់ស៊ើបការពីស្ត្រីនេះ ក៏មិនអាចនឹងសំរេចបានសោះ ដោយអ្នកស្រុកផ្ទះជិតខាងដែលឈឺឆ្អាលនឹងទុក្ខធុរៈគាត់ គេបានមកឡើងចុះផ្ទះនោះមិនដែលដាច់ លុះត្រាតែយប់ស្ងាត់ទៅ ទើបបានរយាលបន្ថិចនូវភ្ញៀវទាំងអស់ហើយ ព្រោះគេបានពិនិត្យឃើញថារបួសដៃរបស់កូនមីងសុខនេះ នឹងបានសះស្បើយក្នុងពេលឆាប់ៗនេះជាមិនខាន ដោយសាស្នាដៃរបស់គ្រូពេទ្យគំបុតដៃនេះ ។ តាំងពីបានទទួលការព្យាបាលរបស់លោក



សាវ័ណ្យមក កុមារឈប់ស្រែកថ្ងូរ ហើយអាស្រ័យបាយខ្លះព្រមទាំងនិទ្រាលក់ស្ងាត់ស្ងៀម ។

– ប្អូន ពីដើមធ្លាប់ធ្វើការក្នុងក្រសួងពេទ្យឬ (ដោយក្រាញ់លួចសួរដោយសម្ងាត់) ឬមួយមានសញ្ញាប័ត្រអ្វីខាងសុខាភិបាលដែរ បានជាចេះចំណាប់ជំនួនម្ល៉េះ

– គ្មានទេបង (លោកអធិការប៉ូលីសជាតិឆ្លើយ) ចំណេះនេះ ខ្ញុំបានពីទន្លេបាទីមក ព្រោះខ្ញុំបានទៅហាត់រៀនចំនួនពីរខែនៅសាលាយុវជនឯទន្លេបាទីនោះ ហើយខ្ញុំបានឆ្លៀតបង្រៀនវិជ្ជានេះជារាល់ថ្ងៃដើម្បីសង្គ្រោះគេក៏ខ្ញុំចេះជាប់មក មួយទៀតមិនជាពិបាកប៉ុន្មានទេឆ្អឹងមនុស្សយើងដែលបាក់ម្តងៗ បើបានគេផ្គុំគ្នាទៅនឹងបានជាប់គ្នាឡើងវិញជានិច្ចនេះឆ្អឹងក្មេងផងឆាប់ណាស់ មិនបាច់ថ្នាំអ្វីសក្តិសិទ្ធទេ ។ កិច្ចយើងគ្រាន់តែធ្វើម្តេចឱ្យឆ្អឹងបាក់នោះនៅស្ងៀម មិនរង្គើកចុះឡើងនោះវាបានហើយ ។ បងឃើញទេ ? ខ្ញុំក្រងព្រួលឫស្សីយកមកអប ហើយឱ្យដាក់ដៃនៅស្ងៀមមួយកន្លែងនេះ គឺដើម្បីការពារមិនឱ្យរង្គើកនោះហើយ ឯថ្នាំប៉ុន្មានមុខដែលខ្ញុំដាក់ឱ្យនេះ មិនជាប្រយោជន៍ប៉ុន្មានទេគ្រាន់តែឱ្យមានធាតុក្តៅផ្សំផងប៉ុណ្ណោះ បើប្រសិនជាកុំឱ្យមានថ្នាំដាក់ផង ក៏ប្រហែលនឹងជាបានដែរឱ្យតែយើង ចេះរុំត្រឹមត្រូវទៅចុះ ។

– បើងចឹងគ្រូឯទៀតដែលដាក់ថ្នាំច្រើនមុខនោះ ប្រហែលជាដាក់ឱ្យតែអ្នកជម្ងឺទុកចិត្តថា ខ្លួនជាគ្រូពូកែប៉ុណ្ណោះទេឬ ?

– យោបល់ខ្ញុំយល់ថាដូច្នោះដែរ ប៉ុន្តែក្រែងតែថ្នាំគេពូកែដោយប្រការយ៉ាងណាទៀតពុំដឹង ព្រោះខ្ញុំពុំមែនជាគ្រូពេទ្យរៀនឱ្យបានជ្រៅជ្រះខាងវិជ្ជានេះឯណា ?

នៅពេលដែលផុតភ្លៀវម្តងៗ គឺក្រោយដែលបានងូតទឹកនឹងអាស្រ័យបាយរួច លោកសាវ័ណ្យនឹងដោយក្រាញអង្គុយជក់បារីនិយាយពីនេះពីនោះលេងជាមួយមីងសុខ ដោយគ្មានកោតក្រែងសោះ ព្រោះអកប្បកិរិយាដែលរៀងខ្លួនបានធ្វើបង្ហាញគាត់នោះ ក៏ល្មមឱ្យគាត់ជឿទុកចិត្តខ្លះហើយ ។

– មីង ! កូនមីងឯងមានផ្លូវជាដូចដើមវិញច្រើនណាស់ (លោកសាវ័ណ្យប្រាប់ទៅម្ចាស់ផ្ទះ) ព្រោះឆ្អឹងបាក់នៅចំកន្លែងដែលខ្ញុំស្រួលមើលមិនអីទេ តែស្នែកនេះមីងឯងនឹងឃើញថាបានស្បើយច្រើន ។

– ចាំះ ! (មីងសុខឆ្លើយ) ខ្ញុំដូចជាមានសំណាងដែរព្រោះបានជួបនឹងលោកគ្រូនេះ ។ ខ្ញុំជាស្រីមិនដឹងទៅរកទីពឹងអ្នកឯណាទេ រំពឹងចាំប្តីខ្ញុំនោះ មិនដឹងជាពេលណានឹងគេមករកផ្ទះសម្បែងវិញទេ គេអាល័យតែផ្កាប់ចៅហ្វាយថ្មីរបស់គេនោះ ។ ខ្ញុំឥឡូវលែងរវល់នឹងដាស់តឿនឱ្យគេហ៊ឺរកធម៌អារ្យអ្វីហើយ ប្តីខ្ញុំមួយខ្ញុំហូតកន្ទុះចោល តាមតែគេបាបកំដោយបានបុណ្យក៏ដោយស្រេចនូវរូបគេហ៎ ។

– តាមមីងឯងស្មាន តើពូគាត់ទៅឯណា ?

– គ្មានទៅណាទេលោកគ្រូអើយ ! បើមិននៅនឹងផ្ទះលោកចៅហ្វាយស្រុកទេក៏នៅនឹង...(គាត់និយាយតិចៗមើលនាយមើលអាល) ក៏នៅ



នឹងបន្ទាយអស់លោកនោះហើយព្រោះឥឡូវលោកសក្តិបីកញ្ចុះ លោកទុកប្តីខ្ញុំដូចជាសេនាជំនិតរបស់គេទៅហើយ គេទៅណាគេយក ទៅតាម ។

– បន្ទាយអស់លោកនោះនៅទីណាទៅមីង ? ឆ្ងាយឬជិតប្រហែលជាសប្បាយណាស់ហើយមើលទៅ ។

– ថីមិនសប្បាយ ខ្ញុំជំរាបតែប៉ុណ្ណេះនេះ លោកគ្រូល្មមស្តាប់បានហើយ មួយទៀតកុំសួរត្រង់នេះ ព្រោះគេហាមផ្តាច់មិនឱ្យនិយាយទៅណាទេ ប៉ុន្តែខ្ញុំស្រឡាញ់លោកគ្រូទេបានជាខ្ញុំនិយាយប្រាប់នេះ លោកគ្រូកុំនិយាយទៅណាវែងឆ្ងាយទៀតណា តែគេដឹងមុខជាត្រូវគេសម្លាប់ហើយ ។

– ខ្ញុំសុំសួរមួយមាត់ចុះ តើនៅដល់ណាមីង ?

– នៅនឹងជើងភ្នំត្បែង ប៉ុន្តែមិនប្រាកដទេ ខ្ញុំឮតែគេថាចំណែកខ្ញុំៗមិនដែលហ៊ានទៅបៀតទេ ។

– ចុះលោកចៅហ្វាយចាស់ មីងឯងជ្រាបយ៉ាងណាទេ ?

– ជ្រាបយ៉ាងម្តេច ! ក្រែងចោរបាញ់លោកស្លាប់ទៅហើយទេឬ?

– ទេ ! ខ្ញុំឮគេថាគ្មានស្លាប់ទេ ពួកអាចោរចាប់យកមកហើយមីងដឹងថាចាប់យកទៅណាទេ ?

- ទេ ខ្ញុំមិនដឹងទេ ប្តីខ្ញុំគ្រាន់តែប្រាប់ថាលោកស្លាប់ប៉ុណ្ណោះ...

ក្នុងពេលនេះ ការសន្ទនារវាងមនុស្សក្នុងផ្ទះនាងសុខដាច់កំបុតដោយសារសន្ទឹកជើងសេះ បន្លឺពីចម្ងាយមក ហើយគេផ្ទៀងស្តាប់តែរៀងខ្លួន ។

– លោកគ្រូចុះទៅពួននៅក្នុងគុម្ពស្លឹកគ្រៃខ្ញុំទៅ កុំនៅមិនបានទេ ព្រោះពួកអស់លោកមកទៀតហើយ (មីងសុខប្រាប់ទៅអ្នកស្នាក់ទាំងពីរ) កុំនៅឱ្យគេឃើញ ក្រែងមានរឿងព្រោះជាអ្នកចំណូលថ្មី ។

សូរជើងសេះកាន់តែឮឡើង ទំនងជាមានមនុស្សប្រហែលជាម្ភៃនាក់ជិះសត្វនេះមក ។ លុះមកជិតបន្តិចក៏បាត់ឮទៅវិញ ឈប់មួយស្របក់ទើបឮទៀត ឮមិនបានប៉ុន្មានក៏ឈប់ទៀត ។

ក្នុងពេលឈប់ម្តងៗនោះ គេឮតែសូរមាត់មនុស្សនិយាយខ្លាំងៗថាៈ "ឱ្យផ្ទះនេះអង្ករមួយតៅ... ផ្ទះនេះប្រាក់មួយពាន់រៀល... ផ្ទះនេះអង្ករមួយដឹក..."

លុះមកដល់ផ្ទះមួយជិតផ្ទះមីងសុខបន្តិច លោកអធិការអាចស្តាប់ឮច្បាស់គ្មានបាត់មួយមាត់ណាទេ ។ ដោយក្រាញ់ប្រាប់លោកថា មាត់ដែលបន្លឺខ្លាំងជាងគេនេះ គឺមាត់អាកញ្ចុះពិតប្រាកដ ។

– អាទិតផ្ទះឯងធំជាងគេ (សក្តិបីកញ្ចុះបង្គាប់ទៅម្ចាស់ផ្ទះ) ត្រូវបង់មួយម៉ឺនរៀល មាសពាដំឡឹង !

– ព្រះគុណម្ចាស់អើយ ! ខ្ញុំបាទគ្មានទេ (ម្នាក់ឈ្មោះទិតអង្វរ) ខ្ញុំបាទមានតែសំបកផ្ទះទេ ស្រូវឆ្នាំនេះធ្វើពុំបានផលសោះ ខ្ញុំបាទមានតែប្រាក់ប្រាំបីរយរៀល ឯមាសមានតែខ្សែកកូនមួយខ្សែប៉ុណ្ណោះ សុំលោកមេត្តាទទួលយកតែប៉ុណ្ណោះទៅចុះ ។

– គ្មានអង្វរ ! នែ ! កនយើងចូលទៅក្នុងផ្ទះ ចាប់យកកូន ក្រមុំវាហើយមើលតើមានសម្បត្តិអ្វីខ្លះ ត្រូវយកមកទាំងអស់ ។



– ព្រះគុណអើយ ! អាណិតកូនខ្ញុំទៅ ព្រះគុណយកអ្វីក៏យកចុះ សុំទុកតែកូនខ្ញុំឱ្យទាន ព្រោះវានៅតូចណាស់ហើយម្តាយឈឺផង បានអ្នកណាបំរើ ។

– កុំនិយាយច្រើន ចាប់វាយកទៅជាមួយផងឱ្យអស់មួយពូជ ។

រួចក៏ឮសូរយំផងស្រែកថ្ងូរផង លាយជាមួយនឹងសូរជើងសេះដែលជញ្រ្ជាំដី ។

នៅផ្ទះមួយទៀត

– អាមាឃ ឯងបិទទ្វាររចង្អៀងទទឹងនឹងអញឬ ? (មេពួកចោរពោល) កនយើងចាំអីមិនពុះទ្វារចូលទៅចាប់វាមក !

– ជំរាបប្រសាសន៍ មិនឃើញទេ (ពួកកូនចោរប្រតិបត្តិរួចចេញមក ឱ្យដំណឹងទៅវិញ) ខ្ញុំបាទរកសព្វហើយ ។

– បើវារត់ចោលផ្ទះ ចូររើយកអីវ៉ាន់វាឱ្យអស់ពីក្នុងផ្ទះហើយដុតផ្ទះវាចោលទៅ ! ។

តែប៉ុណ្ណោះក៏មានពន្លឺភ្លើងភ្លឺភ្លែតៗ រួចឆេះធ្លោលឡើងភ្លឺពេញមេឃ ។ លោកសាវ័ណ្ឌដែលឃើញអំពើអកុសលទាំងនោះ ទ្រាំនៅពួនស្ងៀមពុំបាន ដាច់ចិត្តប្រថុយស្លាប់ រត់ស្ទុះចេញទៅតស៊ូនឹងពួកចោរឱ្យអស់ដៃ ប៉ុន្តែដោយក្រាញ់ដែលជាមនុស្សចាស់គំនិតមានការពិសោធន៍ច្រើនជាង ចាប់ទាញសហជីវិនជាប់ ហើយនិយាយទូន្មានរំលត់ភ្លើងកំហឹងក្តួលក្តៅនោះបានទាន់ពេល ។

មួយរំពេចនោះ ពួកកំណោចមកដល់មុខផ្ទះមីងសុខ ។

មេក្សុខ ! ប្ដីហងទៅណា ? ( កញ្ញុះសួរ ) មានមកដល់ផ្ទះទេ?

– ជំរាបប្រសាសន៍លោកសក្ដិបី មិនឃើញមកទេ ( មីងសុខតប
ក្រែងលោកមានប្រសាសន៍ហៅខ្ញុំប្រុសទៅសាលាស្រុកឬ ? ខ្ញុំស្មាន
តែនៅជាប់នឹងព្រះគុណម្ចាស់ ហើយបានជាខ្ញុំគ្មានទន្ទឹងមើលផ្លូវសោះ
ប៉ុន្តែមកដល់ពេលនេះខ្ញុំឆ្ងល់ដែរ ព្រោះចំឡែកជាងសព្វមួយដង ។

– ទេ ! កុំនិយាយឆ្កួតបែបនេះ អញឯណោឃាត់អាចាន់ឱ្យខាន
មកផ្ទះមួយថ្ងៃមួយយប់ដូច្នេះ ? បានតែព្រើល !

ក្នុងមួយយប់នោះ អ្នកស្រុកភ័យតក់ស្លុតតែរាល់រូប ខំអត់ដង្ហើម
ទំរាំតែបានពួកចោរបាន្ទយុំទាំងនេះ ទៅផុតពីលំនៅដ្ឋានរៀងខ្លួនទៅ ។
បើបានទៅផុតហើយគេគ្មានខូចខាតទ្រព្យច្រើន ឬបង់ជីវិតខ្លួននឹងកូន
ប្រពន្ធទេ នោះគេមានឈ្មោះថាជាអ្នកមានសំណាងមួយធំក្នុងលោកនេះ
ហើយ លុះត្រាតែរំលងអធ្រាតទើបស្ងប់ជើងសេះ ស្ងប់មាត់សន្ទាប់
នឹងមាត់យំសោកព្រមទាំងស្ងប់ស្ងូរឆ្កែព្រូសផង ។

– មីង ! ខ្ញុំឮមាត់ដូចជាសក្ដិបីកញ្ញុះឬ ? ដែលសួរមីងឯងនោះ?
( លោកសាវីណ្យសួរប្រពន្ធគាចាន់ ដោយបញ្ចេញសំឡេងតិចៗ ក្រោយ
ដែលបានចាកចេញពីទីជ្រកពួនមក ) ។

– ហ្អឹងហើយ ! ខ្ញុំមិនច្រឡំទេ ( នារីឆ្លើយ ) ។

– មីងឯងចេះបានរួចពីគ្រោះថ្នាក់ទៅដែរ ។



– ឪមិនរួច ! បើគេត្រូវការប្ដីខ្ញុំ ធ្វើជាបំរើរបស់គេកាលណាគេ
ត្រូវងាប់ បើគេមិនចង់ងាប់ទៅវិញ គេរុញតែប្ដីខ្ញុំទៅ ប្ដីខ្ញុំស្លាប់ជួសគេ
ទៅហើយ ។

– ក្រែងមិនមែនដូច្នោះទេឬ ? តែគេយកយើងទៅធ្វើជាបំរើ
ជនិតគេ គឺគេស្រឡាញ់ពេញចិត្តរបស់គេហើយ ។

– ដឹងជាចិត្តគេយ៉ាងណា ? សុំលោកគ្រូពិរចារណាមើលចុះ
ល្អឬអាក្រក់ ? ក្នុងរូបគេម្នាក់ គេធ្វើការរាជការផងគេធ្វើចោរផង ឱ្យ
ថាល្អត្រង់ណាទៅ ? ប៉ុន្តែប្ដីខ្ញុំវាគ្មានគិតឃើញថាគេល្អអាក្រក់យ៉ាងណា ទេ
គេថាម្ដេចក៏បាន គេប្រើទៅណាក៏ទៅ ខ្ញុំឃាត់ឯណាស្ដាប់ដូចខ្ញុំជំរាប រួចមក

– ចុះស្គាល់គ្នាយូរមកហើយឬ ?

– គ្មានទេ- លោកគ្រូ ! ចាំខ្ញុំជំរាបឱ្យអស់ទៅចុះមុនដំបូងប្ដីខ្ញុំ
នេះមានក្ដីគ្នានឹងឈ្មោះពុត-ជេស ដែលមានផ្ទះនៅខាងចុងភូមិកំពង់ពុទ្រា
នេះពីរឿងដណ្ដើមស្រែគ្នា ។ កាលនោះខ្ញុំឃើញថាប្ដីខ្ញុំខុសដែរ ប៉ុន្តែ
ឃាត់គេមិនស្ដាប់គេទទូចតែក្ដីគ្នា ។ កើតហេតុមិនតិចតួចអី ដល់ទៅ
សាលាដំបូងកំពង់ធំឯណោះ សាលាដំបូងកាត់ឱ្យចាញ់ទៅ ។ តាំងពី
នោះមក ប្ដីខ្ញុំចេះតែពោលថាមិនដឹងគិតធ្វើម្ដេចនឹងបានព្យាបាទអាពុត-
ជេសនេះឱ្យបាន ដល់ក្រោយមកឮថាលោកចៅហ្វាយស្រុកសុគន្ធាផ្លាស់ មក
មានថ្មីដៃខាងដើរចាប់ចោរយកមកធ្វើទោស ឱ្យបានត្រូវៗចិត្តអ្នក ស្រុក
ដែលទទួលរងអំពើប្ដីខ្ញុំក៏លក់គោក្របី យកប្រាក់ទៅជូញក្ដីទៀត ។ ខ្ញុំឮថា
គេហ៊ាទៅជូលដោយកញ្ញុះនេះ ធ្វើពាក្យហើយពឹងពាក់លើវាទៀត ព្រោះវា

ប្រាប់ថាវាជាមនុស្សជំនិតនឹងលោកចៅហ្វាយវានិយាយអ្វីទៅលោកចៅហ្វាយព្រមតាមទាំងអស់ ។

– កាលនោះ ដោយកញ្ចុះបានមកចូលដៃនឹងពួកចោរហើយឬនៅ?

– ខ្ញុំមិនដឹងទេ ប៉ុន្តែត្រូវការអ្វីវាចូលដៃនឹងពួកចោរ បើពួកចោរកាលនោះមានហ៊ានហើបឯណា នៅសំងំពួនតែនឹងភ្នំត្បែងឯណោះ បើសិនជាលោកចៅហ្វាយលោកជ្រាបប្រហែលជាលោកមកវាយកំទិចស្លាប់អស់ទៅហើយ ។

– ចុះសេចក្តីក្នុងពាក្យនោះ ប្តីងថាម៉េចទៅមីងឯងដឹងទេ?

– ខ្ញុំឮប្តីខ្ញុំប្រាប់ថាធ្វើប្តឹងពីពុត-ជេសលួចគោខ្ញុំ មានលួចឯណាចេះតែនាំប្តឹងព្រើលដូច្នោះទៅ ទំរាំតែបានពាក្យនេះឡើងដល់លោកចៅ-ហ្វាយ ប្តីខ្ញុំត្រូវអាកញ្ចុះនាំចាយវាយអស់ប្រាក់ដែលយកទៅគ្មានសល់ ។ រឿងនេះក្រោយដែលយកពាក្យទៅជូនលោកចៅហ្វាយនោះ ខ្ញុំឮគេថាលោកចៅហ្វាយ គ្មានចាប់ឈ្មោះពុត-ជេសមកធ្វើទោសទេ លោកឱ្យនៅក្រៅឃុំហើយបញ្ជូនសំណុំរឿងទៅសាលាដំបូង ប្តីខ្ញុំបានទៅសួរដោយកញ្ចុះ តើម្តេចក៏ដូច្នោះទៅវិញ នោះដោយកញ្ចុះប្រាប់ប្តីថា លោកសុគន្ធាឥឡូវស៊ីសំណូកគេទៅហើយលែងត្រូវនឹងវាហើយ ។ វាឱ្យប្តីខ្ញុំទុកចិត្តលើវាតទៅទៀតវា សន្យាថានឹងធ្វើឱ្យប្តីខ្ញុំសប្បាយចិត្តម្តងដោយសារវាកុំឱ្យប្តីខ្ញុំព្រួយឱ្យសោះ លោកគ្រូមិនជ្រាបទេ កាលពីពេលល្ងាចថ្ងៃច័ន្ទនោះប្តីខ្ញុំត្រឡប់មកពីរវៀង វិញខ្សឹបប្រាប់ខ្ញុំថា "បានការហើយ យប់នេះដឹងគ្នាហើយ" លុះខ្ញុំដឹកសួរ មែនទែនទៅ ទើបគាត់ប្រាប់ខ្ញុំថា អាកញ្ចុះប្រើ



គាត់ឱ្យទៅហៅពួកចោរ ដើម្បីចូលទៅចាប់លោកចៅហ្វាយស្រុកសុគន្ធានោះ បើចោរថាមិនហ៊ាន ទៅ ឱ្យប្រាប់ថាវាបានចាំជួយការពារទាំងអស់ឱ្យពួកចោររកគ្រាប់រំសេវ ទទេដែលមានសំបកដូចគ្រាប់កាំភ្លើងបារាំងឱ្យបានច្រើនប្រគល់មកឱ្យ គាត់ៗ នឹងយកទៅឱ្យអាកញ្ចុះៗ វានឹងប្តូរយកគ្រាប់មែនទែនមកឱ្យពួក ចោរវិញ ហើយយប់នោះឱ្យពួកចោរចូលទៅចុះពួកប៉ូលិសសាលាស្រុក នឹងប្រើតែគ្រាប់រំសេវទទេ កុំឱ្យពួកចោរភ័យ ។

– យី ! ពូចាន់គាត់ចាញ់បោកអាកញ្ចុះដល់ទៅក្បត់ជាតិដូច្នេះ?



– អឺ ! លោកគ្រូអើយ ខ្ញុំឃាត់គេមិនបានទេ តែឃាត់ម្ដងៗ ទៅគេហ៊ានរកវាយរកគក់ព្រោះតែឃាត់ហើយ បានជាតាំងពីថ្ងៃនោះមកខ្ញុំ ខ្ញុំលែងចង់និយាយប្រាប់ខ្ញុំអំពីការអ្វីៗសោះ ។

– ចុះឈ្មោះពុត-ជេសឥឡូវនេះនៅទេឬ ?

– គ្មានទេ ! ពួកចោរសម្លាប់ចោលបាត់ទៅហើយ មិនទាំងឱ្យប្រពន្ធកូនយករូបអសុភមកធ្វើបុណ្យផង មើលទៅប្រហែលជាគ្រូសាខាងពុត-ជេសនេះ ចងពៀរនឹងខ្ញុំជាមិនខាន ខ្ញុំមិនដឹងទេស្រេចតែប្ដីខ្ញុំចុះគេទទួលខុសត្រូវ ចំណែកខ្ញុំសុំតែរួចខ្លួនទេ ។

– អើមីងៗស្គាល់ទេជាងសៅនៅវវៀង

– ជាងសៅធ្វើដែកនោះឬ ?

– ហ្អឹងហើយវាដែលមានរឿងហេតុអីនឹងប្ដីមីងឯងទេ ?

– ខ្ញុំមិនដែលដឹងទេ ប៉ុន្តែខ្ញុំឮប្ដីនិយាយម្ដងដែរថាលោកកញ្ចុះប្រើគាត់ឱ្យតាមសម្លាប់ជាងដែកសៅនេះដែរ មិនដឹងជាមានទោសអ្វីទេ...?

ក្នុងការសន្ទនាដែលបានប្រយោជន៍ច្រើននេះ លោកសាវ័ណ្ឌរកពេលសួរការក្រៅពីនេះពុំបាន លុះត្រាតែចូលជំណោករៀងខ្លួនហើយទើបឆ្លៀតបានខ្លះ ។

– មីង ! កាលលោកសុគន្ធានៅធ្វើការនៅឡើយ មីងឯងដែលទៅមករកលោកទេ ។

– ទេ ! មិនដែលទេ ( នាងសុខឆ្លើយ ) ។



– ចុះមីងឯងដឹងទេ កូនក្រមុំលោក ? លោកលើកឱ្យទៅអ្នកណាហើយ ?

ខ្ញុំមិនដឹងទេ ប៉ុន្តែប្ដីខ្ញុំបានប្រាប់ថាអាកញ្ចុះវាបានចូលស្ដីដណ្ដឹងឱ្យកូនវាធ្វើបាឡាត់នៅកំពង់ធំ ប៉ុន្តែលោកមិនចង់ឱ្យសោះ ព្រោះលោកចង់ទុកឱ្យអ្នកណានោះនៅធ្វើការឯភ្នំពេញ ឮថាធ្វើគិញផង ចំណែកលោកស្រីបែបដូចជាមិនស្រឡាញ់គិញនោះសោះ បែបដូចជាត្រូវចិត្តខាងបាឡាត់ឯណោះអាកញ្ចុះគេចេះតែពោលថា មើលទៅមិនងាយបាននាងនោះមកកូនវាទេ ព្រោះវាដឹងលក្ខណៈរបស់លោកចៅហ្វាយទៅហើយថាជាមនុស្សរឹងប៉ឹងណាស់ ។

– ចុះឥឡូវនេះ មីងដឹងជានាងនោះនៅឯណាទេ ?

– ខ្ញុំមិនដឹងទេ គ្រាន់តែឮថា គេចាប់មកជាមួយនឹងឪពុកទៅហើយ ។

*****

# ជំពូក១៣

## គេហដ្ឋានអាថ៌កំបាំង

លោកអធិការប៉ូលីសជាតិដល់បានឮនាងសុខ ដំណាលពីចិត្តថ្លើម លោកសុគន្ធាចង់ទុកកូនស្រីឱ្យមកខ្លួនហើយ ក៏មានចិត្តរំភើបជាខ្លាំង ។ យប់នោះសម្បជញ្ញៈលោកទៅយកតែរូបលោកមន្ត្រីសប្បុរសនេះមកបង្ហាញខ្លួន ប្រាប់ថានេះហើយគំរូសំរាប់អស់មនុស្សលោក នេះហើយមនុស្សដែលចេះពិចារណាដឹងខុសត្រូវ ចេះមើលមនុស្សណាល្អណាអាក្រក់ មិនឱ្យខុសពីការពិត មិនចេះជឿតែតាមពាក្យញុះញង់ខាងក្រៅ ។ បើក្រៅពីឥស្សរៈជនរូបនេះ មើលទៅប្រហែលជាគេលែងនឹកនាដល់ខ្លួន ដែលមានគុណធមិផ្សេងៗពីគេនេះសោះ ព្រោះគេថាខ្លួនធ្វើការក្នុងក្រសួងពិញក្រសួងដែលគ្មានគេរាប់អាន ។

– មនុស្សល្អយ៉ាងនេះ ខ្ញុំស៊ូប្តូរជីវិតគ្មានស្តាយទេ ។

ពាក្យនេះលោកសាវ័ណ្យទន្ទេញជាប់នៅពេលនិទ្រាផង ។ ប៉ុន្តែដោយអស់កំលាំង ដែលបានខំប្រឹងបញ្ចេញពេញមួយថ្ងៃមកនោះលោកក៏លង់ប្រាណមួយភ្លែតទៅក្នុងដំណេកលក់ទៅ ។ មិនបានប៉ុន្មានក៏ស្រាប់តែភ្ញាក់ខ្លួនព្រើត លោកបើកភ្នែកឡើងឃើញមានមនុស្សជាច្រើនកាន់ចន្លុះព្រោងព្រាត បំភ្លឺពេញតែក្នុងផ្ទះ មីងសុខមិនដឹងជាគេមកពីកាលណាដោយរបៀបយ៉ាងណាទេ លោកស្ទុះក្រោកឡើងគិតគេចខ្លួនប៉ុន្តែ...



– កុំរត់ទៅណា ! (មនុស្សម្នាក់កាន់កាំភ្លើងវែងមួយចង្អុលមាត់ត្រែមកចំ) ក្រោកឡើងដោយស្រួល ហើយទៅតាមយើង ។

– អស់លោកយកខ្ញុំទៅណា ? (សាវ័ណ្យធ្វើជាខ្លបខ្លាចសួរទៅវិញ) ខ្ញុំក្រណាស់លោកអើយ ! មើលចុះខ្ញុំពិការផង រកស៊ីធ្វើការអ្វីបាននឹងគេ ។

– ទៅកុំនិយាយច្រើន !

– សូមទោសលោកអើយ ! ព្រោះខ្ញុំមានធុរៈធំណាស់ (នាងសុខដែលគេគ្មានធ្វើបាបអ្វីនោះលុតជង្គង់អង្វរ) ទុកលោកគ្រូនេះឱ្យនៅមើលកូនខ្ញុំឱ្យជាស្រួលបួលសិន ព្រោះខ្ញុំគ្មានអ្នកណាជាទីពឹងទេ ប្តីខ្ញុំក៏បាត់ខ្លួនទៅផងទៀត ។



– ចុះម្នាក់នោះទុកធ្វើអ្វី ? ក្រែងធ្វើលោកត្រូវដែរឬ (នាយក្រុមកងកំលាំងនេះ ចង្អុលទៅដោយក្រាញ់) យើងទុកឱ្យមើលជម្ងឺកូនអ្នកឯងនេះ ហើយយើងយកទៅតែម្នាក់ទេ ។

ពួកនេះបង្ខំនាំខ្លួនអធិការចេញទៅក្រៅផ្ទះ គ្មានរវល់ស្តាប់ពាក្យលន់តួតទៅទៀតរបស់មឹងសុខឡើយ ។ គេដាក់លោកទៅលើខ្នងសេះមួយដោយគេបានរុំមុខលោកយ៉ាងជិត កុំឱ្យឃើញផ្លូវ រួចគេបំបោលសេះទាំងអស់គ្នានាំលោកចេញពីភូមិចូលទៅក្នុងភាពងងឹត ដោយពួកវា៤នាក់ស្ពាយកាំភ្លើងជិះសេះពីមុខពីក្រោយ ។ លោកសាវីណ្យរកសំគាល់ទិសនឹងចម្ងាយផ្លូវពុំបាន ហើយនឹកព្រួយថា ពួកនេះមិនដឹងយកខ្លួនទៅសម្លាប់ឬធ្វើបាបយ៉ាងណាទេ ប្រហែលជាគេស៊ើបទៅដឹងថាខ្លួនជាអ្នកធ្វើការក្នុងក្រសួងគិញ រួចមកក្លែងខ្លួនបន្លំចូលមកក្នុងភូមិភាគគេហើយ ។ ប៉ុន្តែមិនមែនតក់ស្លុតដល់ទៅញ័រអស់អង្គកាយទេ ព្រោះលោកបានតាំងចិត្តរួចមកហើយថាសេចក្តីស្លាប់នោះមានគ្រោងទុកក្នុងកម្មវិធីនៃបេសកកម្មរបស់លោកស្រាប់ហើយ ។ មួយទៀតលោកមានវ័យនៅក្មេងនៅឡើយ ល្មមលោកតស៊ូបានខ្លះដែរមុននឹងស្លាប់ ។

សេះដើរយូរណាស់មិនដឹងជាពួកវានាំលោកទៅណាទេព្រោះវារុំមុខលោកជិតនាំមិនឱ្យលោកស្គាល់ផ្លូវទៅមក ។ លុះត្រាតែវាបញ្ឈប់សេះហើយវាបើកសំពត់រុំមុខនោះឡើងទើបលោកដឹងថារាត្រីកន្លងផុតទៅហើយៗ ឃើញថាខ្លួនមកដល់ត្រង់មាត់ច្រករបងនៃផ្ទះមួយយ៉ាងសង្ហារសង់កណ្តាលព្រៃស្ងាត់ គ្មានផ្ទះសម្បែងអ្នកស្រុកណានៅជិតឡើយ ។



ងផ្ទះនោះមានជញ្ជាំងឈើប្រក់គ្បឿងទាបជាប់នៅដី ប៉ុន្តែគេតុបតែងឱ្យមានលំអ ដូចគេហដ្ឋាននៃអ្នកមានឬមន្ត្រីធំម្នាក់នៅក្នុងទីក្រុងដែរ ។ នៅមាត់ច្រកនេះ មានជនពីរនាក់ស្លៀកពាក់ដោយឯកសណ្ឋានទាហាន លិកាំភ្លើងលើស្មាឈរជ្រកក្រោមញ៉ាបនៃតូបធ្វើអំពីឈើចំនួនពីរ ដែលសង់អមផ្លូវចូល ។ នៅពេលដែលលោកសាវីណ្យចុះពីសេះនោះ ជនពីរនាក់នេះបញ្ឈរកាំភ្លើងធ្វើគារវកិច្ចចំពោះលោក ហើយមានបុរសម្នាក់ស្លៀកពាក់សមរម្យដូចជាបំរើអ្នកធំ ដើរចេញពីក្នុងរបងផ្ទះនោះមក ឱនកាយគោរពលោកទៀតដោយស្រដីថា :

– សូមលោកអញ្ជើញចូលទៅក្នុងផ្ទះ ព្រោះចៅហ្វាយធំខ្ញុំបាទចាំលោកនៅទីសាឡុង ។

អធិការប៉ូលិសនឹកឆ្ងល់ខ្លាំងណាស់ នូវការគោរពហួសនិស្ស័យហើយនឹងនូវគំនិតពួកមនុស្សដែលនាំខ្លួនលោកមកទីនេះដោយបង្ខំដូច្នេះ ។ ឆ្ងល់ពេកទៅលោកគ្មានបាននឹកនាំនឹងសួរអ្នកបំរើនេះឱ្យដឹងដើមទងឡើយ ។ លុះចូលជាមួយអ្នកបំរើនេះដល់ទ្វារផ្ទះធំ ក៏មានជនម្នាក់ទៀតមាឌធំល្មមប៉ុន្តែមានចំណាស់ជាងលោកបន្តិច ស្លៀកសារុងសូត្រថ្មី ពាក់អាវឃីតរោមចៀមធ្វើពីប្រទេសអឺរុប ហើយដែលអង្គុយជក់បារីបង្អុយធ្វើព្រងើយរបៀបជាអ្នកធំនៅលើកៅអីទ្រាប់ពូកយ៉ាងក្រាស់ ។

– អញ្ជើញមក ! (ជនម្ចាស់ផ្ទះនេះនិយាយមករកលោកសាវីណ្យ) អញ្ជើញអង្គុយលើក្តារឿទៅ !... (ម្ចាស់ផ្ទះចង្អុលប្រាប់ហើយនិយាយថា) ដែលខ្ញុំអញ្ជើញលោកមកនេះ...មកពីខ្ញុំឮល្បីពីអ្នកស្រុកភូមិកំពង់ពុទ្រា

គេថា... ( លោកសាវ័ណ្យប្រុងភ្នែកប្រុងត្រចៀកព្រោះឆ្ងល់ណាស់ )....

– ....គេថាលោកជាគ្រូពេទ្យពូកែណាស់ ចេះមើលកូនក្មេងបាក់ដៃបានសះជាដ៏ស័ក្តិសិទ្ធ តើលោកគ្រូចេះមើលជម្ងឺអ្វីខ្លះទៅ ?

– ទានប្រោសខ្ញុំបាទនេះ គ្មានចេះអ្វីជាណាស់ណាទេចេះត្រឹមតែបាក់ដៃបាក់ជើងប៉ុណ្ណោះអែង ។

– ទេ ! គេថាលោកគ្រូឯងចេះគ្រប់មុខ ប៉ុន្តែមិនអួតអាងទេ ហើយលាក់ខ្លួនណាស់ លុះតែគេបង្ខំខ្លាំងទើបទទួលខ្លួន ខ្ញុំចូលចិត្តតែគ្រូពេទ្យបែបនេះ ខ្ញុំស្អប់ណាស់គ្រូណាដែលដើរអួតថាខ្លួនពូកែគ្រប់ដប់នោះ ។ ហេតុនេះហើយបានជាខ្ញុំឱ្យទាហានទៅអញ្ជើញលោកគ្រូមក ដោយបង្ខំខ្លួនខុសពីជនធម្មតាបើលោកគ្រូនៅតែប្រកែកទៀត ខ្ញុំនឹងគិតឱ្យគេវាយធ្វើបាបលោកគ្រូជាមិនខាន សុំលោកគ្រូកុំប្រកាន់ ។

– ព្រះគុណមិនស្រួលកាយយ៉ាងណាដែរឬ ?

– ទេ ! មេកូនខ្ញុំនោះ វាចេះតែស្គមទៅៗហើយបែបដូចជាចារឹកមិនស្រួលផង ខ្ញុំថប់តែឆ្ងួតលីលាពេញទីទៅទេ ព្រោះសព្វថ្ងៃនិយាយគ្មានដឹងអ្វីសោះទៅហើយ សួរឆ្វេងឆ្លើយស្តាំ ឱ្យទៅស្តាំបែរមកឆ្វេងវិញ យ៉ាងនេះ ខ្ញុំរកគ្រូបួនប្រាំនាក់ហើយមើលមិនជល់សោះ មួយទៀតថ្ងៃខែដែលត្រូវរៀបចំវាក៏ដល់កាន់តែជិតណាស់ទៅហើយ បើនៅតែយ៉ាងនេះទៅធ្វើម្តេចរៀបចំកើតមិនខ្មាស់គេទៅហើយ ?...

– យី ! រោគបែបនេះដូចជាពិបាកដែរ ( លោកសាវ័ណ្យទើបតែបញ្ចេញពាក្យនេះស្រាប់តែជនម្ចាស់ផ្ទះ បើកភ្នែកធំៗចង់សន្ធាប់មក



លោកទៀត ទើបលោកធ្វើជាសួរ ) ទានប្រោស តើវក់បែបនេះមកប៉ុន្មានថ្ងៃហើយ ?

– ទើបតែមួយអាទិត្យនេះទេ ហើយក្នុងថ្ងៃនេះលែងទាំងនិយាយស្តីទៅផងទៀត ។

– សូមទោស ! ព្រះគុណគិតលើកឱ្យទៅអ្នកណាទៅ ?

– ទេ ! ខ្ញុំមិនចូលចិត្តឱ្យសួរច្រើនទេ បើសួរពីកូនខ្ញុំវាឈឺយ៉ាង ម្តេចនោះខ្ញុំប្រាប់បាន ។

– បើដូច្នោះខ្ញុំបាទសុំមើលនាងឱ្យឃើញបានទេ? ( លោកសាវ័ណ្យទាល់ច្រកព្រោះមិនធ្លាប់ ) ។



– មានអី ?

ម្ចាស់ផ្ទះនាំលោកចូលទៅក្នុងបន្ទប់មួយ ដែលមានគ្រឿងប្រើប្រាស់សព្វគ្រប់ ដាក់ដោយសណ្ដាប់ធ្នាប់រៀបរយណាស់ ។ នៅលើគ្រែមាននារីក្រមុំម្នាក់ស្គមស្លឹតស្លាំងទំលាក់សក់ដោយរាត់រាយ ស្លៀកសំពត់អាវទក់ទិកំពុងអង្គុយបត់ជើងថ្វាយបង្គំព្រះលើក្បាលដំណេក ។

– កូនស្រីឪពុក ! លោកគ្រូនេះមកមើលកូនឱ្យជាហើយកូន (ម្ចាស់ផ្ទះហៅនាង) ។

នារីចោលភ្នែកមួយភ្លែត មកមើលលោកសាវ័ណ្យ ហើយងាកទៅវិញយ៉ាងឆាប់ ។ ម្ចាស់ផ្ទះហៅទៀត នាងក៏ងាកមកម្ដងទៀតប៉ុន្តែស្ដោះទឹកមាត់ដាក់ឥដ្ឋ ហើយប្រាស់ខ្លួនទៅលើពូកដណ្ដប់ជួយគ្របមុខធ្វើព្រងើយ ។

លោកសាវ័ណ្យឈរធ្មឹង បញ្ឈរភ្នែកបែបដូចជារកនឹកការអ្វី យូរបន្តិចទើបទម្លាក់ភ្នែកមកធម្មតាវិញ ហើយងក់ក្បាលតិចៗ ។

– អូ ! (លោកលាន់មាត់)

– ម្ដេចលោក ! (ម្ចាស់ផ្ទះសួរ) មើលទៅមានផ្លូវនឹងមើលជាទេ ?

– ទានប្រោស ខ្ញុំបាទនឹកឃើញហើយឈឺបែបនេះ ច្រើនមកតែពីការព្រួយខ្លាំងពេក ឬក៏ត្រូវរបស់គេជាមិនខានមិនអីទេចាំខ្ញុំបាទសាកវិជ្ជាខ្ញុំបាទមើល សុំព្រះគុណឱ្យអ្នកណាយកត្បាល់បុកគ្រឿងមួយមានអង្រែផងហើយរកខ្ទឹមួយកូនមើមនឹងពងមាន់ឆៅប្រាំ ខ្ញុំបាទចេះមើលបែបនេះមកពីកាលដែលខ្ញុំបាទនៅពីតូច ឪពុកម្ដាយបាននាំទៅលេងឯខេត្តតាកែវ



ហើយបានទៅមើលប្រាសាទបាទិ រួចខ្ញុំនេះហេតុតែក្មេងមិនដឹងអ្វី ក៏បានបបួលកូនស្រីជិទង់គេអ្នកស្រុកនោះម្នាក់ទៅអុំទូកលេងក្នុងទន្លេបាទិនោះ ។ លុះអុំលេងអស់ចិត្តត្រឡប់មកវិញស្រាប់តែកូនស្រិគេនោះ ក្ដៅខ្លួនមួយរំពេចមិនដឹងជាខុសអ្វីទេ ធ្វើឱ្យគេភ័យជ្រួលច្របល់អស់ទាំងស្រុក រួចពីក្ដៅខ្លួនទៅស្រាប់តែនិយាយផ្ដេសផ្ដាស ថ្វាយបង្គំព្រះហើយស្ដោះដាក់គេឯងដូចនាងឯចឹង ! កាលនោះមានគ្រូគេពូកែគេមកដាក់ថ្នាំនឹងសូត្ររបៀនឱ្យកូននោះបានសះស្បើយទៅ ។ ឪពុកខ្ញុំបាទបានរៀនចំណេះនេះជាប់រហូតដល់ខ្ញុំបាទធំ ខ្ញុំបាទក៏សុំរៀនពីគាត់តមក ចេះលុះសព្វថ្ងៃនេះ ។

– យី ! បើបានកូនខ្ញុំជាមែន លោកគ្រូចង់បានអ្វីក៏ខ្ញុំឱ្យដែរ ។

– ខ្ញុំបាទមើលនេះរបៀបប្លែកពីគ្រូឯទៀតបន្តិច ខ្ញុំមិនចាំបាច់នៅមើលក្នុងបន្ទប់ជាមួយនឹងមនុស្សជម្ងឺទេ ប៉ុន្តែមានត្រណមបន្តិច ។

– មិនអីទេ ត្រណមយ៉ាងម្ដេចក៏ដោយឱ្យតែបានជា ។

– ខ្ញុំបាទសុំឱ្យខ្ទប់ទ្វារបន្ទប់នេះជានិច្ចកុំចាក់សោ ហើយរកក្មេងតូចម្នាក់អាយុ១០ឆ្នាំគ្រាន់នឹងយកថ្នាំទៅជូននាង អ្នកឯទៀតក្រៅពីក្មេងនេះសុំកុំឱ្យចូលឱ្យសោះ បើគ្រាន់តែបង្ហើបទ្វារមើលពីក្រៅមួយភ្លែតៗនោះបាន ។

លុះវត្ថុដែលឱ្យរកទាំងប៉ុន្មានបានមកសព្វគ្រប់ហើយ លោកគ្រូពេទ្យក្លែងក្លាយនេះ ក៏តាំងក្រាលកន្ទេលផ្ទាល់នឹងឥដ្ឋកំរាល អង្គុយផ្សំថ្នាំនឹងសូត្រមិនដឹងបាលីបាតូអ្វីខ្លះទេ ។ លោកដាក់ខ្ទឹមដែលចិតសំបករួចទៅក្នុងត្បាល់រួចបុកយ៉ាងខ្លាំងៗ ។ លោកបុកបានមួយឬពីរអង្រែក៏សង្កួតអង្រែ

ទៅនឹងមាត់ត្បាល់ម្តងឬពីរដងផង លោកបុកថ្នាំរបៀបនេះយូរបន្តិចទៅក៏ឈប់ស្ងៀមហើយផ្លុំខ្ទីនោះម្តង ។ ផ្លុំយូរបន្តិចក៏តាំងបុកត្បាល់នឹងសង្កួតអង្រែនេះទៀត ។ ម្ចាស់ផ្ទះអង្គុយលើកៅអីមួយជិតនោះមើលមកលោកគ្មានហ៊ានចោលភ្នែកទៅណាក្នុងពេលដែលលោកឈប់ដៃម្តងៗ គេអាចឮសូរមាត់កូនក្រមុំដែលឈឺនោះស្រែកពីក្នុងបន្ទប់មកថា «យ៉ ! អីក៏ដូចចិនសែបុកថ្នាំម្លេះ?» រួចពីស្រែកនេះនាងធ្វើត្រាប់សូរបុក នឹងសង្កួតមាត់ត្បាល់នោះ ។

– លុះបុកខ្ទីរួចហើយ លោកដាក់ខ្ទីនោះចូលទៅក្នុងកែវហើយគោះស៊ុតមាន់ទាំងប្រាំដាក់ចូលលាយនឹងខ្ទី · រួចប្រើក្មេងឱ្យយកទៅជូននាងក្រោយដែលបានធ្វើមាត់អូចៗនឹងផ្លុំដាក់មាត់កែវ ។

– ព្រះគុណអញ្ជើញទៅអើតមើលៗ ( លោកនិយាយទៅកាន់ម្ចាស់ផ្ទះ) តើមានឃើញបានការខ្លះទេ ?

– អើហ្ន៎ ! ផឹកថ្នាំរួច ស្រាប់តែចេះក្រោកឡើងទៅឈរមើលកញ្ចក់រៀបសក់ស្រួលបួល ( ម្ចាស់ផ្ទះលាន់មាត់ដោយបានលបមើលយ៉ាងយូរ) ចេះប្រើក្មេងឱ្យយកទឹកមកលប់មុខដុសធ្មេញ ខុសពីរាល់ថ្ងៃមែន !

– នេះមិនទាន់ជាដាច់តែម្តងទេ ចាំខ្ញុំបានមើលបន្តិចទៀតសិនឱ្យបានជ្រះស្រឡះតែម្តង ។

– ហ្នឹងហើយ ! សុំលោកគ្រូមើលឱ្យអស់ចិត្តចុះ ។

តាំងពីនោះមកម្ចាស់ផ្ទះនេះឧស្សាហ៍ទៅអើតមាត់ទ្វារនាង ហើយសួរពីនេះពីនោះដើម្បីពិសោធន៍មើល ។ កាលបើឃើញនាងឆ្លើយត្រឹម-



ត្រូវតាមសំនួរគាត់ហើយ គាត់ក៏ញញឹមជាប់ ។ ជួនកាលគាត់ពោលថា «តែប៉ុណ្ណេះស្រេចហើយ ! វានៅជាមួយគ្នាជាប្តីប្រពន្ធបានហើយ» ។ គាត់ឱ្យលោកសាវ័ណ្យទៅសំរាកកំលាំងនៅនឹងបន្ទប់មួយដែលនៅទំនេរ ។

លុះពេលថ្ងៃត្រង់ លោកសាវ័ណ្យបានមកបាយទឹកជាមួយម្ចាស់ផ្ទះក្នុងពេលដែលនាងកញ្ញាអាស្រ័យនៅខាងក្នុងបន្ទប់ម្នាក់ឯង ។

– កូនស្រីព្រះគុណ មើលទៅមិនសូវស្រឡាញ់ប្តីទេ ( លោកបានពោល) ព្រោះខ្ញុំបាទ មើលឃើញដល់ក្នុងចិត្តនាងទៅផងទៀត ។

– លោកគ្រូនិយាយដូចជាត្រូវ អ្នកធំនោះឆ្លើយតប) ប៉ុន្តែចិត្តខ្ញុំស្រឡាញ់តែកូនប្រសាមួយហ្នឹង តើឱ្យខ្ញុំធ្វើម្តេច?

– មានពិបាកអ្វី ? ចាំខ្ញុំបាទធ្វើក្រមួនដន្លាប់ជូនគ្រាន់ព្រះគុណទុកឱ្យកូនលោកលាបថ្ពាស ស្រីៗមិនងាយទប់បាននឹងក្រមួនស្នេហ៍ខ្ញុំបាទនេះទេ ។

– គ្រាន់បើចេះធ្វើស្នេហ៍ !

– ខ្ញុំបាទមិនដែលប្រាប់អ្នកណាទេ ប៉ុន្តែបានមកឃើញព្រះគុណដែលអាចឱ្យតែខ្ញុំបាទមានចិត្តស្រឡាញ់នេះ ខ្ញុំបាទមិនលាក់ទេ ។ ខ្ញុំបាទមិនមែនចេះតែប៉ុណ្ណេះទេ សូម្បីតែប្រក់ពលក៏ខ្ញុំបាទចេះ....

– ចេះប្រក់ពល ? ៗ ?

– បើព្រះគុណត្រូវការឱ្យខ្ញុំបាទប្រក់ជូន ខ្ញុំបាទមិនរួញរាទេនៅពេលបាយរួចនេះ ខ្ញុំបាទនឹងរៀបចំគ្រឿងសក្ការៈបូជា សុំព្រះគុណចាត់ទាហានបួនប្រាំនាក់ឱ្យជួយខ្ញុំបាទ ព្រោះត្រូវការធ្វើរានខ្ពស់ពីដី ហើយ

បំពេញកិច្ចរញ៉ីករញ៉ុកណាស់ ព្រះគុណចាំមើលឱ្យតែប្រក់ពលរួច ពួក
ទាហានលោក បើសិនជាទៅច្បាំងឯណាតែងមានជ័យជំនះដរាប ។

– ចេះធ្វើឱ្យបំបាំងបាត់ទេ ?

– ទានប្រេសបំបាំងនេះស្រួលសោះ គឺទន្ទេញតែបាលីពីរបីម៉ាត់ ទេ
បាលីនោះហៅថាមេសូត្រ «តេជោដំឌិន» ប៉ុន្តែត្រូវរៀបគ្រឿងសក្ការៈ
ដូចរបៀបប្រក់ពលដែរ ។

– បើងចឹង ថ្ងៃនេះយើងប្រក់ពលផង រៀបបំបាំងផង ដើម្បីកុំឱ្យគេ
បាញ់ត្រូវយើង ហើយគេមើលយើងពុំឃើញ ។

– ប្របាទកុំព្រួយ ចំណែកកូនស្រីព្រះគុណនេះគង់តែនឹងបានជា
ស្រឡះ ប៉ុន្តែនៅអស់កំលាំងបន្តិច ចាំមើលថ្ងៃនេះខ្ញុំបាទផ្សំថ្នាំឱ្យនាងគេង
បានទើសល្ងាច ក្រោកឡើងកាលណានឹងមានកំលាំងជាងដើម ។

ពេលម៉ោងពីររសៀលថ្ងៃសៅរ៍នោះ ដោយធាតុរងាមកគ្របដណ្ដប់
ជនគ្រប់រូប ពួកទាហាននៃគេហដ្ឋាននេះព្រួតគ្នាជួយធ្វើរានម៉ានឹងរកគ្រឿង
គ្រប់ប្រការ ឱ្យលោកគ្រូបានទាន់ពេល ។ នៅក្រោមអធិបតីភាពនៃម្ចាស់
ផ្ទះដ៏មានអំណាចពួកទាហានប្រហែលសែសិបនាក់សុទ្ធតែស្លៀកក្រមា អង្គុយ
តម្រៀបគ្នា សំពះនឹងចាំឱ្យលោកគ្រូកំបុតដៃស្រោចទឹកឱ្យម្ដងម្នាក់ៗ ។ ទំរាំ
តែរួចកិច្ចគ្រប់សព្វនោះ ម៉ោងជាង៤រសៀលទៅហើយ ។

– អូ ! ខ្ញុំបាទភ្លេចកន្សែងយ័ន្តនៅកំពង់ពុទ្រាទៅហើយ (លោកគ្រូ
ប្រាប់ទៅម្ចាស់ផ្ទះ) ខ្ញុំបាទចង់ទៅកំពង់ពុទ្រាមួយភ្លែត ដើម្បីយកកន្សែង
នោះមកចំឡងចែកពួកទាហានគ្រប់គ្នា ។



– មានអី ? (ម្ចាស់ផ្ទះឆ្លើយ) ចាំខ្ញុំឱ្យគេជូនទៅ ។

– ខ្ញុំបាទចង់ជិះសេះទៅម្នាក់ឯងវិញ ព្រោះខ្លាចខុសគ្រូណម មួយ
ទៀតសុំឱ្យអស់លោកទាំងអស់អង្គុយភាវនាថ្វាយបង្គំព្រះឱ្យបានដប់ចប់សិន
សឹមអញ្ជើញទៅរកស្លៀកពាក់ទំរាំខ្ញុំបាទមកដល់ សឹលចូលពេញខ្លួនតែម្ដង ។

តាំងពីលោកសារីល្បជិះសេះផុតយូរបន្តិចទៅ ម្ចាស់ផ្ទះដើរញញឹម
តែម្នាក់ឯង ពីមុខទៅក្រោយ ពីក្រោយទៅមុខហើយមិនភ្លេចអើតមើល
ទៅក្នុងបន្ទប់កូនក្រមុំទេ ។ គាត់ឃើញនាងនៅតែនិទ្រាគ្រលំភួយលើគ្រែ ។
ឯក្មេងបំរើក៏និទ្រាលក់ស្កប់ស្កល់ដែរ ។

នាឡិកាវាយម៉ោង៦ ហើយវាយ៧ទៀត ក៏គាត់នៅតែឃើញនាង
និទ្រាដដែលៗ គាត់ទឹកឆ្ងល់ខ្លាំងណាស់ ឯលោកគ្រូក៏មិនឃើញវិលមកវិញ ។
ចុះនាងនិទ្រាអ្វីក៏យូរខ្លាំងម្លេះ ។ ក្មេងបំរើភ្ញាក់មុន បានចេញមកលេងខាង
ក្រៅហើយបានទាំងទៅរកបាយទឹកផងទៀត ។ គាត់សង្ស័យណាស់ក្រែង
នាងនិទ្រាលក់ពេកទៅៗជាស្លាប់តែម្ដង ក៏ប្រថុយឱ្យខុសគ្រូណមលោកគ្រូ
ចូលទៅដាស់នាងដល់គ្រែ ។ នាងគ្មានឆ្លើយសោះគាត់ភ័យណាស់ចាប់ផ្ទួយ
បើកមើលមុខកូន ។ ពុទ្ធោអើយ ! គាត់ឃើញអ្វី ? គាត់ឃើញតែខ្នើយឱប
ទទេនៅក្នុងផ្ទួយនោះ ។ ទើបគាត់ស្រែកប្រាប់ពួកទាហានថា :

– នែវើយ ! កូនក្រមុំអាសុគន្ធារត់បាត់ទៅហើយ ចេញសេះទៅគ្រប់
ច្រករកចាប់វា នឹងចាប់អាកំបុតមកវិញឱ្យបាន !

– សូមលោកសក្ដិបីកុំព្រួយ (ពួកទាហានចោរប្រចាំការនាយកញ្ចុះ
ជិះសេះចេញពីគេហដ្ឋានក្នុងអាថិកំបាំងនេះ ព្រោងព្រាតចូលទៅក្នុងព្រៃ ។